**Declassified to Public**
**12 June 2020**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Aug-2016, 14:12
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស/ខ្មែរ [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**
មុំ លុដ្ឋ
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីយឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១២ អតីតសហចៅក្រមអន្តរជាតិដែលខ្ញុំជំនួសតំណែង និង សហចៅក្រមស៊ើបអង្កេតជាតិ បានណែនាំអ្នកស៊ើបអង្កេតរបស់ខ្លួន ថា លែងតម្រូវឲ្យថតយកសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទៀតហើយ[1]។

៣. នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ បន្ទាប់ពីមានសំណើពីមេធាវីការពារក្តី អ៊ឹម ចែម មក អតីត សហចៅក្រមអន្តរជាតិដែលខ្ញុំជំនួសតំណែង បានដាក់ចូលសំណុំរឿង ០០៤ នូវខ្សែអាត់សំឡេងចំនួន ៤២០ នៃកំណត់ហេតុនៃការស្តាប់ចម្លើយ("កំណត់ហេតុស្តាប់ចម្លើយ") ដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០១, ០០២ និង ០០៣ និងជាផ្នែកមួយនៃភស្តុតាងនៅក្នុងសំណុំរឿង ០០២[2]។

៤. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចាប់ផ្តើមឡើងវិញនូវការអនុវត្តថតយកសំឡេងនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់[3]។ នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចេញសេចក្តីណែនាំស្តីពីការសម្រិតសម្រាំងការស្តាប់ចម្លើយសាក្សី[4]។ នៅក្នុងអនុស្សរណៈដដែលនេះ ខ្ញុំបានណែនាំអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី គួរតែសរសេរឡើង

---

[1] សំណុំរឿង 004 ឯកសារ D116 *សេចក្តីណែនាំស្តីពីការស្តាប់ចម្លើយសាក្សី* ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២។

[2] សំណុំរឿង 004 ឯកសារ D250 *ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម លេខ D247 និង D249* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២។

[3] សំណុំរឿង 004 ឯកសារ D266 សេចក្តីណែនាំស្តីពីការថតការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២២ កញ្ញា ២០១៥។

[4] ការសម្ភាសន៍ដើម្បីសម្រិតសម្រាំងគឺជាការសន្ទនាជាបឋមរវាងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ជាមួយនឹងសាក្សីសក្តានុពល ដើម្បីកំណត់ថាតើជននោះអាចមានព័ត៌មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរដែរឬអត់។

01312303



វិញឲ្យដូចអ្វីដែលបាននិយាយនៅក្នុងអំឡុងពេលស្តាប់ចម្លើយ ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន[5]។

៥. នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្ដី បានដាក់*សំណើសុំការបកប្រែ និងការធ្វើប្រតិចារឹកនៃខ្សែអាត់ថតសំឡេង និងសំណើដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង*(" សំណើ")[6]។

II. **សារណា**

**ក. វិការៈដែលបានចោទនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ**

៦. នៅក្នុងសំណើ មេធាវីការពារក្ដី អះអាងថា ខ្លួនបានរកឃើញភាពមិនត្រឹមត្រូវយ៉ាងច្រើនទាក់ទងនឹងខ្សែអាត់សំឡេង និងកំណត់ហេតុស្ដាប់ចម្លើយដែលស្ថិតនៅក្នុងប្រភេទវិការៈដូចខាងក្រោម[7]។

i. <u>សំណួរនាំមុខ</u>

៧. មេធាវីការពារក្ដី ចោទថា ក្នុងករណីខ្លះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងអ្នកបកប្រែផ្ទាល់មាត់ បានសួរសំណួរនាំមុខដែលមិនបានកត់ត្រាថាជាសំណួរនាំមុខឡើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ហើយសួរសំណួរនាំមុខដែលផ្ដល់ឲ្យសាក្សីនូវចម្លើយដែលអ្នកស៊ើបអង្កេតរំពឹងថានឹងទទួលបាន[8]។

៨. បន្ថែមពីលើនេះទៀត មេធាវីការពារក្ដី អះអាងថា ភស្តុតាងត្រូវបានបំប្លែងនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ដើម្បីបង្ហាញឲ្យឃើញថា សាក្សី កំពុងតែផ្ដល់ភស្តុតាងតាមការចងចាំរបស់ខ្លួន

---

[5] សំណុំរឿង 00៤ ឯកសារ D269 *សេចក្ដីណែនាំស្ដីពីការសម្រិតសម្រាំងដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្ដីពីទម្រង់នៃកំណត់ហេតុស្ដាប់ចម្លើយ* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥។

[6] សំណុំរឿង 00៤ ឯកសារ D274 *សំណើសុំការបកប្រែ និងការធ្វើប្រតិចារឹកនៃខ្សែអាត់ថតសំឡេង និងសំណើសុំដាក់ឯកសារមួយចំនួនក្នុងសំណុំរឿង* ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៥។

[7] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២ និង ៣០។

[8] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៤-៤០។

01312304



តែតាមពិត សាក្សីបញ្ជាក់តាមការលើកឡើងដែលអ្នកស៊ើបអង្កេត បានប្រាប់ពួកគាត់តែប៉ុណ្ណោះ[9]។

ii. <u>ការខកខានមិនបានកត់ត្រាភស្តុតាងដោះបន្ទុក</u>

៩. មេធាវីការពារក្តី បង្ហាញពីករណីនានាដែលពាក្យពេចន៍ពិតប្រាកដរបស់សាក្សី មិនបានបកប្រែដោយអ្នកបកប្រែភាសាជាលាយលក្ខណ៍អក្សរ ឬក៏មិនបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយឡើយ[10]។ ហេតុនេះ មេធាវីការពារក្តី បញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយ ដកចេញនូវភស្តុតាងដោះបន្ទុក ឬព័ត៌មានដែលអាចប៉ះពាល់ដល់ដំណើររឿងរបស់សាក្សី[11]។

iii. <u>ការបំផ្លើស ការកត់ត្រាពុំត្រឹមត្រូវ និងការបំប្លែងភស្តុតាង</u>

១០. មេធាវីការពារក្តី អះអាងថា កំណត់ហេតុស្តាប់ចម្លើយ ជាទូទៅបំប្លែងភស្តុតាង[12]។ ការបំប្លែងនេះមានរាប់តាំងពីកំណត់ហេតុស្តាប់ចម្លើយដែលមានព័ត៌មាន ដែលមិនបាននិយាយនៅក្នុងអំឡុងពេលស្តាប់ចម្លើយ រហូតដល់កំណត់ហេតុស្តាប់ចម្លើយដែលបំផ្លើសផ្នែកមួយចំនួននៃព័ត៌មានដើម្បីធ្វើឲ្យព័ត៌មាននោះបង្ហាញឲ្យឃើញថាកាន់តែដាក់បន្ទុក[13]។ បន្ថែមពីលើនេះទៀត មេធាវីការពារក្តី អះអាងថា ក្នុងករណីដែលខ្សែអាត់សំឡេងដែលថតសម្តីរបស់សាក្សីបង្ហាញឃើញថាមានភាពមិនស៊ីសង្វាក់គ្នាចំពោះភស្តុតាងរបស់សាក្សី ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយវិញ បែរជាបង្កើតឲ្យឃើញថាមានភាពស៊ីសង្វាក់គ្នាទៅវិញ[14]។

iv. <u>ការស្តាប់ចម្លើយត្រូវបានរៀបចំទុកជាមុន និង"ក្រៅផ្លូវការ"</u>

១១. មេធាវីការពារក្តី អះអាងថា តាមរយៈការស្តាប់ចម្លើយមួយចំនួន បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា អ្នកស៊ើបអង្កេត និងអ្នកបកប្រែផ្ទាល់មាត់ និយាយសំដៅលើការសន្ទនាមួយដែលបានកើត

---

[9] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៩ និង ៤០។

[10] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤១-៤៤។

[11] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤១។

[12] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៥-៤៩។

[13] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៥,៤៧ និង ៤៨។

[14] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៦ និង ៤៩។

ឡើងមុនពេលការស្តាប់ចម្លើយ ប៉ុន្តែ ពុំមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬខ្សែអាត់សំឡេងនៃការសន្ទនានោះទេ[15]។ ក្នុងករណីមួយ មេធាវីការពារក្តី អះអាងថា អ្នកបកប្រែផ្ទាល់មាត់ បានអានអត្ថបទមួយផ្នែកធំឲ្យសាក្សីស្តាប់ ដែលនេះគឺជានាំមុខលើបញ្ហាខ្លឹមសារ ចំណែកឯ កំណត់ហេតុស្តាប់ចម្លើយ វិញ មិនបានលើកឡើងពីការសន្ទនាមុននោះឡើយ ហើយក៏មិនបានកត់ត្រាលក្ខណៈសំណួរនាំមុខដែរ[16]។

v. <u>បុគ្គលមិនស្គាល់អត្តសញ្ញាណ</u>

១២. មេធាវីការពារក្តី អះអាងថា បុគ្គលនានាដែលមិនបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ឧស្សាហ៍មានវត្តមាននៅពេលស្តាប់ចម្លើយ ហើយនៅពេលខ្លះ ចូលរួមចំណែកក្នុងការស្តាប់ចម្លើយផងដែរ[17]។ ឧទាហរណ៍ មេធាវីការពារក្តី បង្ហាញពីករណីដែលព័ត៌មានទទួលបានពីការចូលរួមចំណែករបស់ជនមិនស្គាល់អត្តសញ្ញាណម្នាក់ បានបញ្ចូលទៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែ ហាក់ដូចជាបង្ហាញថា សាក្សីបានផ្តល់ព័ត៌មាននោះទៅវិញ និងករណីផ្សេងទៀតដែលសាក្សី ទទួលរងឥទ្ធិពលពីជនមិនស្គាល់អត្តសញ្ញាណ[18]។

## ខ. ដំណោះស្រាយដែលស្នើសុំ

១៣. មេធាវីការពារក្តី អះអាងថា ដោយសារថា កំណត់ហេតុស្តាប់ចម្លើយ ពុំមានភាពត្រឹមត្រូវ ហើយធ្វើឲ្យភាន់ច្រឡំ ទើបចាំបាច់ត្រូវផ្តល់ការបកប្រែជាលាយលក្ខណ៍អក្សរឲ្យបានពេញលេញប្រកបដោយវិជ្ជាជីវៈចំពោះប្រតិចារឹកនៃការស្តាប់ចម្លើយ ដើម្បីលើកកម្ពស់សិទ្ធិរបស់ អោ អាន ក្នុងការទទួលបានសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងដើម្បីធានាថា មេធាវីការពារក្តី មានលទ្ធភាពត្រឹមត្រូវក្នុងការពិនិត្យមើលភស្តុតាងប្រឆាំង អោ អាន[19]។ មេធាវីការពារក្តី កត់សម្គាល់ថា ខ្លួនមិនមានសមត្ថភាព ឬធនធានដើម្បីត្រួតពិនិត្យ និងបកប្រែ

---

[15] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០-៥២។

[16] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៣។

[17] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៤។

[18] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៤-៥៥។

[19] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៦-៥៧។

ខ្សែអាត់សំឡេង និងបង្កើតប្រតិចារឹកពេញលេញប្រកបដោយវិជ្ជាជីវៈដោយខ្លួនឯងបានឡើយ [20]។

១៤. ជាងនេះទៀត មេធាវីការពារក្តី អះអាងថា វិការៈកិច្ចស៊ើបសួរដែលបានបង្ហាញ គឺពាក់ព័ន្ធនឹងការវាយតម្លៃថាតើ ក.ស.ច.ស បានគោរពតាមកាតព្វកិច្ចរបស់ខ្លួនតាមវិធានផ្ទៃក្នុង ៥៥(៥) ដើម្បីបំពេញកិច្ចស៊ើបសួរឥតលម្អៀងក្នុងគោលបំណងដើម្បីបញ្ជាក់ការពិតដែរឬអត់[21]។

១៥. មេធាវីការពារក្តី បញ្ជាក់ថា វិការៈកិច្ចស៊ើបសួរទាំងនេះផ្ទុយពីសេចក្តីណែនាំនាពេលថ្មីៗរបស់ខ្ញុំដែលឲ្យ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវកម្រិតការសួរសំណួរ និងធានាថា កំណត់ហេតុស្តាប់ចម្លើយដែលផ្អែកលើការស្តាប់ចម្លើយ ត្រូវកត់ត្រាឡើងវិញឲ្យដូចដើមនឹងអ្វីដែលបាននិយាយក្នុងអំឡុងពេលស្តាប់ចម្លើយ ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន[22]។ មេធាវីការពារក្តី អះអាងថា កំណត់ហេតុស្តាប់ចម្លើយដែលមិនបានឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវអំពីសំណួរដែលអ្នកស៊ើបអង្កេត ឬអ្នកបកប្រែផ្ទាល់មាត់ បានចោទសួរ ឬចម្លើយរបស់សាក្សីនោះ គឺជាការរំលោភបំពានមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[23]។

១៦. មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា ចាំបាច់ត្រូវដោះស្រាយវិការៈទាំងនេះនៅដំណាក់កាលនេះ ដោយពិនិត្យឃើញថា ដីកាដំណោះស្រាយ កែតម្រូវវិការៈទាំងអស់នៅក្នុងកិច្ចស៊ើបសួរ និងដោយពិនិត្យមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា នៅពេលដែលមានការអះអាងថា កំណត់ហេតុស្តាប់ចម្លើយត្រូវបានបំប្លែងខ្លឹមសារចម្លើយ និងធ្វើឲ្យរាំងស្ទះកិច្ចស៊ើបសួរ ដោយចេតនា និងដោយបានដឹងឮនោះ ភាគីគប្បីដាក់សំណើទៅអង្គបុរេជំនុំជម្រះ សុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ឬកិច្ចស៊ើបសួរទាំងមូលដោយអនុលោមតាមវិធានផ្ទៃក្នុង ៧៦[24]។

---

[20] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣, ៥, ៣១ និង ៥៦។

[21] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៨។

[22] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៩។

[23] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៩-៦០។

[24] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨។

១៧. ហេតុនេះ ដើម្បីធានាសិទ្ធិរបស់ អោ អាន និងដើម្បីជាប្រយោជន៍យុត្តិធម៌ ទើបមេធាវីការពារក្តី ស្នើថា ស.ច.ស គួរ៖

ក. បង្គាប់ឲ្យបកប្រែ និងធ្វើប្រតិចារឹកឲ្យដូចដើមឲ្យបានពេញលេញប្រកបដោយវិជ្ជាជីវៈ ចំពោះខ្សែអាត់សំឡេងដែលមេធាវីការពារក្តី បង្ហាញថា ពាក់ព័ន្ធយ៉ាងសំខាន់ជាមួយនឹងសំណុំរឿង ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយនឹងសំណើ។

ខ. ដាក់ចូលសំណុំរឿងនូវខ្សែអាត់សំឡេងនៃកំណត់ហេតុស្តាប់ចម្លើយចំនួនបីក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ គ និង

គ. ដាក់ឯកសារបកប្រែ និងប្រតិចារឹកទាំងអស់នៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្ទេរពីសំណុំរឿង ០០១, ០០២ និង ០០៣ ចូលក្នុងសំណុំរឿង ០០៤[25]។

## III. ពិភាក្សា

១៨. ខ្ញុំបានត្រួតពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹក និងខ្សែអាត់សំឡេងដែលមេធាវីការពារក្តី បានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក និង ខ ភ្ជាប់ជាមួយនឹងសំណើ។ មុនពេលពិភាក្សាលទ្ធផលនៃការត្រួតពិនិត្យរបស់ខ្ញុំ ជាដំបូង ខ្ញុំធ្វើការអង្កេតជាទូទៅមួយចំនួនអំពីវិធានដែលអនុវត្តចំពោះការកត់ត្រាការស្តាប់ចម្លើយនៅ អ.វ.ត.ក ដែលពាក់ព័ន្ធនឹងការវាយតម្លៃលើការចោទប្រកាន់អំពីភាពពុំត្រឹមត្រូវរបស់ មេធាវីការពារក្តី។

### ក. ការអង្កេតជាទូទៅអំពីការស្តាប់ចម្លើយ

i. <u>ការកត់ត្រាការស្តាប់ចម្លើយ</u>

១៩. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចេញសេចក្តីណែនាំទៅអ្នកស៊ើបអង្កេតទាំងអស់របស់ ក.ស.ច.ស ថា កំណត់ហេតុស្តាប់ចម្លើយ ត្រូវសរសេរឡើងវិញឲ្យដូចអ្វីដែលបាន

[25] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥-៦ និង ៨។

និយាយនៅក្នុងអំឡុងពេលស្តាប់ចម្លើយ ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន[26]។ ប៉ុន្តែ សេចក្តីណែនាំទាំងនេះ មិនមែនជាបទដ្ឋានអប្បបរមាសម្រាប់វាយតម្លៃលើភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយឡើយ។

២០. វិធានផ្ទៃក្នុង ផ្តល់ការណែនាំតិចតួចអំពីទម្រង់ និងខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយ។ វិធានទាំងនេះគ្រាន់តែចែងថា *"រាល់ការស្តាប់ចម្លើយ ឬសួរយកចម្លើយទាំងអស់របស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ"*[27]។ មាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងលម្អិតជាងនេះក្នុងនោះ រួមមាន កំណត់ហេតុស្តាប់ចម្លើយ *"ស្រង់យ៉ាងត្រឹមត្រូវនូវសំណួរចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង"*។ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា *"អនុលោមតាមទម្លាប់អនុវត្តទូទៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការស្តាប់ចម្លើយចំពោះមុខ ក.ស.ច.ស ពុំមែនជាកំណត់ហេតុឥតលម្អៀងឡើយ ប៉ុន្តែវាជារបាយការណ៍ដែលសហចៅក្រមស៊ើបអង្កេត បានរៀបចំស្តីពីចម្លើយពាក់ព័ន្ធរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬជនជាប់ចោទ"*[28]។ ក្នុងការពន្យល់អំពីការអនុវត្តតាមច្បាប់កម្ពុជា អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឲ្យបានច្បាស់ឡើយ ហើយក៏មិនបានយោងលើអំណាចណាផ្សេងទៀតឡើយ។ ប៉ុន្តែ វត្តមានរបស់ចៅក្រមកម្ពុជាប្រកបវិជ្ជាជីវៈបីរូបនៅអង្គជំនុំជម្រះនេះ គឺជាភស្តុតាងល្អគ្រប់គ្រាន់បញ្ជាក់ថា ទម្លាប់របស់តុលាការកម្ពុជា ក្នុងការអនុវត្តមាត្រា ២៤២ នៃក្រមនីតិព្រហ្មទណ្ឌកម្ពុជា គឺជាអង្គហេតុមួយដែលអង្គជំនុំជម្រះសាលាដំបូង បានដឹងឮ។ ទម្លាប់អនុវត្តនេះអនុញ្ញាតឲ្យមានវិធីសង្ខេបកំណត់ហេតុស្តាប់ចម្លើយ ដរាបណា សេចក្តីសង្ខេបនេះឆ្លុះបញ្ចាំងយ៉ាងសមរម្យអំពីការឆ្លើយឆ្លងគ្នារវាងចៅក្រម ឬអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី។ ចំណុចនេះក៏មានការបញ្ជាក់ថែមទៀតតាមរយៈយោបល់ពីសហសេវិកជាតិរបស់ខ្ញុំ នៅពេលដែលពិគ្រោះយោបល់ទាក់ទងនឹងការអនុវត្តរបស់តុលាការកម្ពុជាជាទូទៅ និងការបកប្រែខ្លឹមសារដើមនៃសំណៅ

---

[26] សំណុំរឿង ០០៤ ឯកសារ D269 *សេចក្តីណែនាំស្តីពីការសម្រិតសម្រាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្តីពីទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥។

[27] វិធានផ្ទៃក្នុង ៥៥(៧)។

[28] សំណុំរឿង ០០២ ឯកសារ E142/3 *សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ស.ច.ស* ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ដាក់នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១១។

ដើមមាត្រា ២៤២។ តាមសំណៅជាភាសាខ្មែរនៃមាត្រា ២៤២(២)នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា *កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំណួរ ចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង* ជាភាសាអង់គ្លេស (*"the written record correctly extracts the questions, answers, and spontaneous statement"*)។ តាមវចនានុក្រមភាសាខ្មែរសម្តេច ជួន ណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ពាក្យថា ស្រង់ មានន័យជាភាសាអង់គ្លេស *"to extract or to excerpt"* [29]។ ហេតុនេះ ការសង្កត់ធ្ងន់នៅមាត្រា ២៤២ គឺពាក្យថា "យ៉ាងត្រឹមត្រូវ" មិនមែនមានន័យថាដូចគ្នាទាំងស្រុងជាមួយនឹងអ្វីទាំងអស់ដែលបាននិយាយឡើយ។ ការយល់ឃើញនេះគឺស្របគ្នាផងដែរជាមួយនឹងការអនុវត្តច្បាប់របស់បារាំង ដែលជាគំរូរបស់ប្រព័ន្ធច្បាប់កម្ពុជា[30]។

២១. ហេតុនេះ ខ្ញុំជឿជាក់ថា ចំពោះបទដ្ឋានអប្បបរមាផ្នែកច្បាប់ កំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងក្នុងអំឡុងពេលស៊ើបសួរនៅ អ.វ.ត.ក ជាស្ថាប័នតុលាការមួយរបស់កម្ពុជា គឺមិនចាំបាច់មានចម្លើយដូចសម្តីដើមទាំងស្រុងឡើយ ហើយអាចរៀបចំសេចក្តីព្រាងជាទម្រង់របាយការណ៍អំពីភស្តុតាងពាក់ព័ន្ធដែលសាក្សីបានផ្តល់ឲ្យនៅពេលស្តាប់ចម្លើយ។ ប៉ុន្តែសេចក្តីសង្ខេបអំពីការឆ្លើយឆ្លងគ្នារវាងអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី ត្រូវតែអាចប្រើប្រាស់បានដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវអំពីភាពអាចជឿជាក់បាន និងតម្លៃភស្តុតាងដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ជាទម្លាប់អនុវត្តល្អ នេះគឺជាមូលហេតុដែលខ្ញុំបានបង្ហាញការពេញចិត្តឲ្យមានកំណត់ហេតុដូចសម្តីដើម ហើយបានណែនាំ អ្នកស៊ើបអង្កេត ឲ្យធ្វើដូច្នេះ តែ នេះមិនគួរច្រឡំជាមួយនឹងការកំណត់បទដ្ឋានអប្បបរមាថ្មី ហើយកាន់តែខ្ពស់ផ្នែក*ច្បាប់* សម្រាប់រៀបចំកំណត់ហេតុស្តាប់ចម្លើយឡើយ។

### ii. <u>សំណួរនាំមុខនៅក្នុងការស្តាប់ចម្លើយ</u>

២២. អ.វ.ត.ក មានមូលដ្ឋានលើគំរូច្បាប់ស៊ីវិល ដែលកិច្ចស៊ើបសួរធ្វើឡើងដោយចៅក្រមឥតលម្អៀងដែលមិនមានប្រយោជន៍ពីលទ្ធផលណាមួយនៃកិច្ចស៊ើបសួរឡើយ គឺខុសពីភាគីនៅក្នុង

---

[29] សម្តេចសង្ឃ ជួន ណាត *វចនានុក្រមភាសាខ្មែរជួន ណាត* វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០១១។

[30] *សូមមើល* Droit et Pratique de l'instruction préparatoire, Dalloz 2010-2011, 114.11 សម្រាប់សាក្សី, 114.21 សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និង 114.44 – 45 សម្រាប់ទាំងសាក្សី ទាំងដើមបណ្តឹងរដ្ឋប្បវេណី។

កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌគោលការណ៍ចំពោះមុខ។ យោងតាមវិធានផ្ទៃក្នុង ៥៥(៥) ករណីយកិច្ចរបស់ ស.ច.ស គឺត្រូវបញ្ជាក់ការពិតទាក់ទងនឹងអង្គហេតុដែលសហព្រះរាជអាជ្ញា បានចោទ។

២៣. តាមវិធានផ្ទៃក្នុង មិនមានការហាមឃាត់មិនឱ្យប្រើប្រាស់សំណួរនាំមុខឡើយ ហើយចៅក្រមនៅ អ.វ.ត.ក បានប្រកាន់យកគោលជំហរផ្សេងៗគ្នាអំពីភាពអាចទទួលយកសំណួរបែបនេះ។ អង្គជំនុំជម្រះសាលាដំបូង មិនអនុញ្ញាតឱ្យមានសំណួរនាំមុខ[31] ចំណែកឯ អង្គជំនុំជម្រះតុលាការកំពូល វិញ គ្រាន់តែហាមមិនឱ្យប្រើប្រាស់សំណួរបែបនេះតែ *"នៅក្នុងប្រធានដែលមានលក្ខណៈចម្រូងចម្រាស"* ប៉ុន្តែទុកផ្លូវឱ្យមានលទ្ធភាពប្រើប្រាស់សំណួរនាំមុខសូម្បីតែនៅក្នុងប្រធានបទបែបនោះក៏ដោយ គឺអាស្រ័យតាមការអនុញ្ញាតជាមុនរបស់ចៅក្រម[32]។

២៤. ដោយផ្អែកលើបទពិសោធន៍ជាមួយនឹងកិច្ចស៊ើបសួរសំណុំរឿង ០០៣ និង ០០៤ ការហាមឃាត់ទាំងស្រុងមិនឱ្យប្រើប្រាស់សំណួរនាំមុខ ឬសំណួរបិទ នឹងមិនល្អឡើយដើម្បីបញ្ជាក់ការពិតនៅក្នុងសំណុំរឿង ០០៤។ ដោយសារមានភាពខុសគ្នាខាងវប្បធម៌ ការអប់រំ និងសាវតាររបស់សាក្សី វ័យជរា ឬក៏កត្តាទាំងនេះរួមបញ្ចូលគ្នា ទើបសាក្សី ប្រហែលជាមិនអាចយល់បានភ្លាមៗអំពីប្រភេទព័ត៌មានដែលអ្នកស៊ើបអង្កេតកំពុងស្វែងរកតាមរយៈការសួរសំណួរឡើយ។ នៅក្នុងកាលៈទេសៈបែបនេះ អ្នកស៊ើបអង្កេត អាចបង្ខំចិត្តផ្តល់ភាពលម្អិតបន្ថែមទៀត ដោយសួរសាក្សីនូវសំណួរតូចៗមួយចំនួន ឬក៏ពេលខ្លះ ថែមទាំងផ្តល់លទ្ធភាពចម្លើយមួយចំនួនផងដែរ។ នៅពេលខ្លះទៀត អ្នកស៊ើបអង្កេត អាចសម្រេចប្រើប្រាស់សំណួរនាំមុខ ឬសំណួរបិទ ដើម្បីពិនិត្យមើលភាពអាចទុកចិត្តបាន ឬភាពអាចជឿជាក់បានរបស់សាក្សី។ ហេតុនេះ ទោះបីថា ជារឿយៗភាគច្រើនបំផុត គួរប្រើប្រាស់សំណួរបើក យ៉ាងណាក៏ដោយ ក៏ពេលខ្លះចាំបាច់ត្រូវប្រើប្រាស់សំណួរនាំមុខ ឬសំណួរបិទដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធ។

---

[31] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ ឯកសារ E1/54.1 *ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨០ [អង់គ្លេស]។ សំណុំរឿង ០០២ ឯកសារ E1/61.1 *ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២* ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ១០ [អង់គ្លេស]។

[32] សំណុំរឿង ០០២ ឯកសារ F26 *សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ* ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ១(ក)។

iii. ការស្តាប់ចម្លើយក្រៅផ្លូវការដែលមិនបានធ្វើកំណត់ហេតុ

២៥. វិធានផ្ទៃក្នុង ៥៥(៧) ចែងថា រាល់ការស្តាប់ចម្លើយ ឬស្តួរយកចម្លើយទាំងអស់ជាមួយនឹងសាក្សីត្រូវធ្វើកំណត់ហេតុ។ នេះគឺជាអនុវត្តរបស់ ស.ច.ស និងអ្នកស៊ើបអង្កេតរបស់ខ្លួនចំពោះការស្តាប់ចម្លើយទាំងអស់។ ខ្ញុំមិនបកស្រាយវិធានផ្ទៃក្នុង ៥៥(៧) ដើម្បីរាប់បញ្ចូលទាំងការសន្ទនាជាបឋមជាមួយនឹងសាក្សី ដែលជួនកាលត្រូវធ្វើឡើងដើម្បីកំណត់ថាតើ ជនណាម្នាក់ មានព័ត៌មានពាក់ព័ន្ធដែរឬអត់ ហើយបន្ទាប់មក កំណត់ថាតើគួរតែបែងចែកធនធានដើម្បីស្តាប់ចម្លើយជននោះជាផ្លូវការដែរឬអត់។ ខ្ញុំបានផ្តល់សេចក្តីណែនាំយ៉ាងច្បាស់ទៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការអនុវត្ត និងដែនកំណត់នៃទំនាក់ទំនងជាបឋមបែបនោះ[33] ប៉ុន្តែ សេចក្តីណែនាំទាំងនេះគឺផ្អែកលើអ្វីដែលខ្ញុំយល់ឃើញថាជាការអនុវត្តដ៏ល្អ។ ទំនាក់ទំនងជាបឋមជាមួយសាក្សីដែលមិនបានធ្វើកំណត់ហេតុមិនរំលោភបំពានវិធានផ្ទៃក្នុង ៥៥(៧)ឡើយ។

iv. វត្តមានរបស់បុគ្គលមិនស្គាល់អត្តសញ្ញាណ

២៦. វិធានផ្ទៃក្នុង ៥៦(១) ចែងអំពីគោលការណ៍រក្សាការសម្ងាត់កិច្ចស៊ើបសួរ។ ស្របតាមគោលការណ៍នេះ វិធានផ្ទៃក្នុង ៦០(២) ចែងថា ការស្តាប់ចម្លើយត្រូវធ្វើឡើងនៅទីកន្លែង និងក្នុងរបៀបមួយដែលការពារការសម្ងាត់។

២៧. ប៉ុន្តែ នៅពេលដែលអ្នកស៊ើបអង្កេត នៅតំបន់ជនបទ មិនមែនតែងតែអាចរកបានបន្ទប់បិទជិតដើម្បីស្តាប់ចម្លើយសាក្សី និងមិនឲ្យសមាជិកគ្រួសារ ឬអ្នកជិតខាងរបស់អ្នកផ្តល់ចម្លើយមកនៅជិតក្រុមការងារស្តាប់ចម្លើយបានឡើយ។ តាមរយៈបទពិសោធន៍ចុះដល់ទីកន្លែងរបស់អ្នកស៊ើបអង្កេត ខ្ញុំយល់ថា ជាក់ស្តែង មិនអាចលុបបំបាត់ករណីបែបនេះបានទាំងស្រុងឡើយ។ ជាងនេះទៀត មិនមែនតែងតែអាចរារាំងអ្នកដែលនៅជិតក្រុមការងារស្តាប់ចម្លើយ មិនឲ្យបញ្ចេញអារម្មណ៍ភ្ញាក់ផ្អើល ឬមិនឲ្យស្ម័គ្រចិត្តប្រាប់រឿងហេតុការណ៍របស់ខ្លួន ទាក់ទងនឹងសំណួរដែលសួរសាក្សីនៅពេលស្តាប់ចម្លើយឡើយ។ នៅក្នុងកាលៈទេសៈបែបនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវតែចាត់វិធានការចាំបាច់ និងសមហេតុផលភ្លាមៗដើម្បីបញ្ឈប់

[33] សំណុំរឿង ០០៤ ឯកសារ D269 *សេចក្តីណែនាំស្តីពីការសម្រិតសម្រាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្តីពីទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥។

ការជ្រៀតជ្រែកបែបនេះ ហើយប្រសិនបើអ្នកស៊ើបអង្កេតសម្រេចថា ការជ្រៀតជ្រែកនោះជះឥទ្ធិពលមកលើសាក្សី គាត់នឹងកត់ត្រាបញ្ហានោះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។

## ខ. វិភាគវិការៈដែលមេធាវីការពារក្តី បានចោទនៅក្នុងឧបសម្ព័ន្ធ ក និង ខ ភ្ជាប់ជាមួយនឹងសំណើ

២៨. នៅក្នុងឧបសម្ព័ន្ធ ក និង ខ ភ្ជាប់ជាមួយនឹងសំណើ មេធាវីការពារក្តី បានចោទថាមានវិការៈចំនួន ១១២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយចំនួន ២៦។ នៅពេលដែលត្រួតពិនិត្យមើលបញ្ហាទាំងនោះ ខ្ញុំជឿជាក់ថា ភាគច្រើនលើសលុបក្នុងចំណោមបញ្ហាទាំងនោះគឺអនុវត្តតាមវិធានដែលចែងអំពីការស្តាប់ចម្លើយ នៅ អ.វ.ត.ក ហើយល្អមអាចត្រឹមត្រូវ និងអាចជឿជាក់បាន។ ខ្ញុំគ្រាន់តែបង្ហាញករណីមួយចំនួនតូចដែលការប្តឹងតវ៉ានានារបស់មេធាវីការពារក្តី មានហេតុផល។

i. <u>សំណួរនាំមុខ និងការស្តាប់ចម្លើយក្រៅផ្លូវការ</u>

២៩. មេធាវីការពារក្តី បង្ហាញទាំងច្រឡំថាជាសំណួរនាំមុខ ឬជាការលើកយោងលើការស្តាប់ចម្លើយពីមុនដែលមិនបានធ្វើកំណត់ហេតុចំពោះករណីមួយចំនួនដែលតាមការពិត អ្នកបកប្រែផ្ទាល់មាត់ អានកំណត់ហេតុស្តាប់ចម្លើយឲ្យសាក្សីស្តាប់ឡើងវិញ យោងតាមវិធានផ្ទៃក្នុង ៥៥(៧)[34]។ មិនមែនមិនត្រឹមត្រូវទេ នេះគឺជាការអនុវត្តដែលត្រូវធ្វើនៅក្នុងការស្តាប់ចម្លើយទាំងអស់ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក្នុងគោលបំណងដើម្បីធានាសុក្រឹតភាពនៃកំណត់ហេតុស្តាប់ចម្លើយ តាមរយៈការអនុញ្ញាតឲ្យសាក្សីពិនិត្យឡើងវិញលើចម្លើយរបស់គាត់ ហើយប្រសិនចាំបាច់ ធ្វើការកែតម្រូវ និងបន្ថែម។ ក្នុងករណីមួយទៀត អ្នក

---

[34] *សូមមើល* ឧបសម្ព័ន្ធ ក៖ វិការៈដែលចោទ ១.១ ដល់ ៨.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វង សុគន្ធ (D3/19)។ ឧបសម្ព័ន្ធ ខ៖ វិការៈដែលចោទ ១.១ ដល់ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ខែក ញ៉ៅ (D107/11) វិការៈដែលចោទ ១.១ ដល់ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី គៀន ឡី (D107/12) វិការៈដែលចោទ ១.១ ដល់ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុង សុខៃ(D107/13) វិការៈដែលចោទ ១.១ ដល់ ៧.១ និង ៩.១ ដល់ ១១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី បាន សៀក (D107/15)។

ស៊ើបអង្កេតសំដៅលើការសន្ទនាសម្រិតសម្រាំងជាមុនសិនជាមួយនឹងសាក្សី[35] ដែលមិនចាំបាច់តម្រូវឲ្យកត់ត្រាដែរតាមវិធានផ្ទៃក្នុង។

៣០. ក្នុងករណីប៉ុន្មានផ្សេងទៀតដែលបានត្រួតពិនិត្យខាងលើនេះ មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ មិនបានកត់ត្រាសំណួរដែលមានលក្ខណៈនាំមុខ ឬក៏ចោទថា ភស្តុតាងដែលសាក្សីបានផ្តល់ឲ្យ តាមពិតគឺជាបង្កើបឡើងរបស់អ្នកស៊ើបអង្កេត។

*ការស្តាប់ចម្លើយសាក្សី វង សុគន្ធ (D107/4)*

៣១. មេធាវីការពារក្តី ចោទថា នៅក្នុងការស្តាប់ចម្លើយសាក្សី វង សុគន្ធ អ្នកស៊ើបអង្កេត បាននាំមុខសាក្សី ចំពោះពេលវេលានៃការចាប់ខ្លួនឪពុកគាត់។ នេះមិនមែនជាបញ្ហាឡើយ ពីព្រោះថាអ្នកបកប្រែផ្ទាល់មាត់ បានសួរសំណួរនោះទៅសាក្សី ជាលក្ខណៈសំណួរបើកចំហថា៖ *"តើលោកស្រី អាចប្រាប់យើងបានថាតើឪពុកលោកស្រី ត្រូវគេចាប់ខ្លួននៅឆ្នាំណា?"* ហើយសាក្សីបានឆ្លើយសំណួរនេះដោយឯករាជ្យ និងរក្សាចម្លើយនៅដដែលទោះបីជាក្រោយមកអ្នកបកប្រែផ្ទាល់មាត់បានសួរបន្ថែមអំពីពេលវេលានេះក៏ដោយ[36]។ នេះគឺជាករណីមួយដែលមេធាវីការពារក្តី ចោទថាមានវិការៈនៅក្នុងការប្រាស្រ័យទាក់ទងគ្នារវាងអ្នកស៊ើបអង្កេតជាមួយនឹងអ្នកបកប្រែផ្ទាល់មាត់ តែ មេធាវីការពារក្តី ត្រូវពិចារណាឡើវិញលើរបៀបដែលការប្រាស្រ័យទាក់ទងគ្នានេះធ្វើឡើងរវាងអ្នកបកប្រែផ្ទាល់ ជាមួយនឹងសាក្សី។

*ការស្តាប់ចម្លើយសាក្សី ស្នួន កានិល( D29)*

៣២. មេធាវីការពារក្តី ចោទថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk បាននាំមុខសាក្សី ចំពោះអង្គហេតុដែលថា អោ អាន គឺជាលេខាតំបន់ ១ និងជាអនុលេខាភូមិភាគកណ្តាល[37]។ តាមពិត ចៅក្រម Blunk គ្រាន់តែសួរឲ្យសាក្សី បញ្ជាក់ពីភស្តុតាងដែលគាត់បានផ្តល់ឲ្យនៅ

---

[35] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ផ្លុង សាន (D3/16)។

[36] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១០.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វង សុគន្ធ (D107/4)។

[37] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ស្នួន កានិល(D29)។

ក្នុងការស្តាប់ចម្លើយពីមុន[38]។ ស្រដៀងគ្នានេះដែរ មេធាវីការពារក្តី ចោទថា ចៅក្រម Blunk បាននាំមុខសាក្សី ចំពោះកាលបរិច្ឆេទនៃការមកដល់របស់ អោ អាន ដោយសួរថា "*តើអាចនៅចុងឆ្នាំ ១៩៧៧ ឬនៅដើមឆ្នាំ ១៩៧៨?*" ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយកត់ត្រាចំណុចនេះជាសំណួរចំហថា "តើលោកបានស្គាល់ តា អាន ទេ?"[39]។ ចៅក្រម Blunk មិនបានបង្ហើបពេលវេលាដែល អោ អាន មកដល់ ប្រាប់សាក្សីឡើយ។ គាត់បានរំឭកឡើងវិញអំពីភស្តុតាងរបស់សាក្សីនៅក្នុងការស្តាប់ចម្លើយពីមុន ដែលសាក្សីបានបញ្ជាក់ថា ពួកនិរតីមកដល់ "*ប្រហែលជាចុងឆ្នាំ ១៩៧៧ និងដើម ១៩៧៨*"[40]។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)*

៣៣. មេធាវីការពារក្តី ប្តឹងថា កំណត់ហេតុស្តាប់ចម្លើយ មិនមានកត់ត្រាលក្ខណៈនៃសំណួរនាំមុខ និងអង្គហេតុដែលថា មានការស្តាប់ចម្លើយពីមុនជាមួយសាក្សីដដែលនេះដែលមិនបានធ្វើកំណត់ហេតុ[41]។ នៅថ្ងៃទី ១ នៃការស្តាប់ចម្លើយសាក្សីរូបនេះបានចាប់ផ្តើមនៅម៉ោង ២.២០ រសៀល ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២[42] នៅពេលដែលបកប្រែសំណួរមួយរបស់អ្នកស៊ើបអង្កេត អ្នកបកប្រែផ្ទាល់មាត់ បាននិយាយសំដៅលើការស្តាប់ចម្លើយ "*ព្រឹកនេះ*"[43]។ ប៉ុន្តែ អ្នកស៊ើបអង្កេត មិនបាននិយាយអ្វីឡើយអំពីការស្តាប់ចម្លើយនៅព្រឹកនោះ ដូច្នេះ មិនច្បាស់ថាតើអ្វីដែលអ្នកបកប្រែផ្ទាល់មាត់និយាយសំដៅលើទេ[44]។ ក្រោយពីបានពិភាក្សាបញ្ហានេះ

---

[38] *សូមមើល* សំណុំរឿង ០០៤ ឯកសារ D6.1.697 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ERN 00373496-00373497 ដែលសាក្សី បញ្ជាក់ថា អោ អាន គឺជាលេខាតំបន់ ៤១ ហើយក្រោយមកត្រូវបានតែងតាំងជាអនុលេខាភូមិភាគកណ្តាល។

[39] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សួន កានិល(D29)។

[40] សំណុំរឿង ០០៤ ឯកសារ D6.1.707 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ERN 00390076។

[41] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ២.១ និង ២.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។

[42] សំណុំរឿង ០០៤ ឯកសារ D107/8R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី ញឹម កុល* ម៉ោង ០១.២៩.00 ដល់ ០១.២៩.១៦។

[43] សំណុំរឿង០០៤ ឯកសារ D219/422.4 *ប្រតិចារិកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01121128។

[44] ដូចជើងទំព័រខាងលើ។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D107/8R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី ញឹម កុល* ម៉ោង ០១.៥២.៥០- ០១.៥៣.១៥។

ជាមួយនឹងអ្នកស៊ើបអង្កេត និងអ្នកវិភាគដែលបានធ្វើការស្តាប់ចម្លើយនោះរួចមក ការពន្យល់ទំនងបំផុតអំពីបញ្ហានេះគឺថា អ្នកបកប្រែផ្ទាល់មាត់ អាចនិយាយសំដៅលើការសន្ទនាសម្រិតសម្រាំងជាបឋមជាមួយសាក្សីដែលបានធ្វើឡើងនៅព្រឹកនោះ ដែលតាមរយៈនេះ អ្នកស៊ើបអង្កេត បានដឹងថា កងទ័ពភូមិភាគនិរតីបានមកដល់មុនពួករដ្ឋបាល។ ខ្ញុំបានណែនាំអ្នកស៊ើបអង្កេត ឲ្យកម្រិតសំណួរដែលសួរនៅក្នុងដំណាក់កាលសម្រិតសម្រាំងបែបនេះ ហើយធ្វើកំណត់ហេតុការស្តាប់ចម្លើយជាបឋមបែបនេះនៅក្នុងរបាយការណ៍ស្តីពីកិច្ចស៊ើបសួរ[45] ប៉ុន្តែនៅពេលដែលការស្តាប់ចម្លើយនេះបានធ្វើឡើង អ្នកស៊ើបអង្កេត មិនបានស្ថិតនៅក្រោមសេចក្តីណែនាំបែបនោះឡើយ។

៣៤. នៅក្នុងការស្តាប់ចម្លើយដដែលនោះ មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ "*មិនបានកត់ត្រាថា អ្នកស៊ើបអង្កេតកំពុងព្យាយាមប្រាប់សាក្សីអំពីរបៀបឆ្លើយសំណួរឡើយ*"[46]។ ជាពិសេស មេធាវីការពារក្តី បញ្ជាក់ថា នៅក្នុងប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយនេះ អ្នកស៊ើបអង្កេត ត្រូវបានថតសំឡេងនិយាយថា "*ដូច្នេះ សំណួរបន្ទាប់ គឺ៖ តើគាត់ចូលរួមយ៉ាងសកម្មក្នុងការចាប់មនុស្ស ការបោសសម្អាត? ដូច្នេះ ឥឡូវ អ្នកនឹងឆ្លើយ៖ ចាស ចាប់តាំងពីពេលគាត់មកដល់ គាត់បានចាប់ផ្តើមចាប់មនុស្សជារៀងរាល់យប់*"[47]។ ប៉ុន្តែ ប្រតិចារឹកពីរទំព័រមុនពេលចម្លើយនេះ បញ្ជាក់យ៉ាងច្បាស់ថា តាមពិត អ្នកស៊ើបអង្កេតសង្ខេបខ្លឹមសារចម្លើយរបស់សាក្សី នៅក្នុងការឆ្លើយឆ្លងគ្នាយ៉ាងវែងជាមួយនឹងអ្នកបកប្រែផ្ទាល់មាត់[48]។ ហេតុនេះ ការចោទប្រកាន់របស់ មេធាវីការពារក្តី មកលើអ្នកស៊ើបអង្កេតអំពីការប្រព្រឹត្តិខុសធ្ងន់ធ្ងរនោះ គឺមិនមានមូលដ្ឋានឡើយ។

---

[45] សំណុំរឿង ០០៤ ឯកសារ D269 *សេចក្តីណែនាំស្តីពីការសម្រិតសម្រាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្តីពីទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១។

[46] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៦.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។

[47] សំណុំរឿង០០៤ ឯកសារ D219/422.5 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01136880-01136881[អង់គ្លេស]។

[48] សំណុំរឿង០០៤ ឯកសារ D219/422.5 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01136880-01136881[អង់គ្លេស]។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល( D107/8)*

៣៥. មេធាវីការពារក្តី ប្តឹងថា អ្នកស៊ើបអង្កេត បានសួរថា *"ដូច្នេះ មានន័យថា ស្រុកទទួលបញ្ជាពីតំបន់ដើម្បីចាប់មនុស្ស?"*[49] ប៉ុន្តែ សំណួរដែលបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺថា *"តើថ្នាក់ស្រុកមានដែលទទួលបញ្ជាពីថ្នាក់តំបន់ទេ"*[50]។ ដោយពិចារណាលើការផ្លើយឆ្លងគ្នារវាងសាក្សី ជាមួយនឹងអ្នកស៊ើបអង្កេតមុនពេលសួរសំណួរនេះ ដូចបានពន្យល់ខាងក្រោម ខ្ញុំមិនយល់ស្របតាមសេចក្តីព្រួយបារម្ភរបស់មេធាវីការពារក្តី អំពីរបៀបដែលសំណួរនេះបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយឡើយ។ អ្នកស៊ើបអង្កេតបានសួរសំណួរនាំមុខក្នុងគោលបំណងដើម្បីបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងភស្តុតាងរបស់សាក្សី។ សំណួររបស់អ្នកស៊ើបអង្កេត បានសួរបន្ទាប់ពីសាក្សីបានបញ្ជាក់ថា តំបន់មិនដែលបញ្ជូនមនុស្សទៅចាប់ខ្លួនឡើយ[51]។ ទោះយ៉ាងណា មុនពេលផ្តល់ចម្លើយនេះបន្តិច សាក្សីបានប្រាប់អ្នកស៊ើបអង្កេត ថា តំបន់មានមន្ទីរសន្តិសុខផ្ទាល់ខ្លួន ហើយកម្មាភិបាលដែលមានតួនាទីមួយចំនួននៅពេលដែលត្រូវបានចាប់ខ្លួន គឺបានបញ្ជូនមកតំបន់[52]។ ហេតុនេះ ជាការត្រឹមត្រូវ និងស្របតាមករណីយកិច្ចរបស់ ស.ច.ស ក្នុងការស្វែងរកការពិត ដែលអ្នកស៊ើបអង្កេត ស្វែងរកការបញ្ជាក់បំភ្លឺអំពីតួនាទីរបស់តំបន់ ទាក់ទងនឹងការចាប់ខ្លួន។

*ការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ( D3/10)*

៣៦. មេធាវីការពារក្តី ប្តឹងថា កំណត់ហេតុស្តាប់ចម្លើយសាក្សី នីវ ស៊ុន មិនបានកត់ត្រាលក្ខណៈនៃសំណួរនាំមុខចំនួនពីរលើក។ ក្នុងករណីទាំងពីរនេះ អ្នកស៊ើបអង្កេតបានសួរសំណួរមួយចំនួនមានបំណងបញ្ជាក់ពីសំណួរពីមុនដែលបានសួរសាក្សី។

---

[49] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១០.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)។

[50] សំណុំរឿង ០០៤ ឯកសារ D107/8 *កំណត់ហេតុនៃការស្តាប់ចម្លើយ ញឹម កុល* ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN 00784986។

[51] សំណុំរឿង០០៤ ឯកសារD219/422.4 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01136789-01136790[អង់គ្លេស]។

[52] សំណុំរឿង០០៤ ឯកសារD219/422.4 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01136784-01136787[អង់គ្លេស]។

៣៧. ក្នុងករណីទី ១ អ្នកស៊ើបអង្កេតពន្យល់ទៅអ្នកបកប្រែផ្ទាល់មាត់ អំពីព័ត៌មានដែលគាត់កំពុងស្វែងរក ដោយសួរសំណួរ ឧទាហរណ៍ អំពីប្រភេទការងារនៅកងកុមារ[53]។ ខ្ញុំជឿជាក់ថា របៀបដែលសំណួរនេះបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺជាសេចក្តីសង្ខេបអាចជឿជាក់បានអំពីការឆ្លើយឆ្លងគ្នារវាងអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី។

៣៨. ក្នុងករណីទី ២ អ្នកស៊ើបអង្កេតបានព្យាយាមបញ្ជាក់អំពីព័ត៌មានដែលគាត់កំពុងស្វែងរក ដោយបង្ហើបប្រាប់សាក្សី អំពីពេលវេលា។ កំណត់ហេតុស្តាប់ចម្លើយ ផ្តល់ជាសេចក្តីសង្ខេបអាចជឿជាក់បានអំពីការឆ្លើយឆ្លងគ្នារវាងអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី[54]។

*ការស្តាប់ចម្លើយសាក្សី ណៃ ស៊ី (D3/11)*

៣៩. មានការចោទប្រកាន់ស្រដៀងគ្នាចំនួនពីរទាក់ទងនឹងការស្តាប់ចម្លើយ ណៃ ស៊ី។

៤០. ក្នុងករណីទី ១ អ្នកស៊ើបអង្កេតបានស្វែងរកការបញ្ជាក់អំពីកាលបរិច្ឆេទ។ ក្រៅពីនេះទៀត កាលបរិច្ឆេទដែលអ្នកស៊ើបអង្កេតបានបញ្ជាក់ មិនបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយឡើយ[55]។

៤១. មេធាវីការពារក្តី ក៏មិនត្រឹមត្រូវដែរក្នុងការចោទប្រកាន់ថា ការស្តាប់ចម្លើយមួយដែលមិនបានធ្វើកំណត់ហេតុ បានធ្វើឡើងមួយថ្ងៃមុនកំណត់ហេតុស្តាប់ចម្លើយ[56]។ ដោយមិនបានយោងលើការស្តាប់ចម្លើយដែលមិនបានធ្វើកំណត់ហេតុទេ អ្នកស៊ើបអង្កេតបែរជាដេញដោលសាក្សី ដោយលើកឡើងពីចម្លើយដែលអ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញា ( "ក.ស.ព") បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៦។ ការស្តាប់ចម្លើយរបស់ ក.ស.ព គួរតែបានលើកយោងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដើម្បីងាយស្រួលជាឯកសារយោង ប៉ុន្តែនៅក្នុងផ្នែកនៃការស្តាប់ចម្លើយដែលមេធាវីការពារក្តី បានធ្វើប្រតិចារឹក អ្នកស៊ើបអង្កេត

---

[53] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី នីវ ស៊ុន (D3/10)។

[54] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី នីវ ស៊ុន (D3/10)។

[55] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ ស៊ី (D3/11)។

[56] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ និង ៣.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ ស៊ី (D3/11)។

01312318



លើកយោងយ៉ាងច្បាស់សំដៅលើ"របាយការណ៍"[57]។ ការស្រាវជ្រាវតាម Zylab ស្វែងរក "ណៃ ស៊ី" ឃើញភ្លាមៗនូវការស្តាប់ចម្លើយពីមុននេះ[58]។

*ការស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)*

៤២. ចំពោះការចោទប្រកាន់អំពីភាពមិនត្រឹមត្រូវនៅក្នុងការស្តាប់ចម្លើយ ដួង ស៊ីម អ្នកស៊ើបអង្កេតគ្រាន់តែផ្តល់ឧទាហរណ៍មួយចំនួនដែលអាចមានប្រាប់សាក្សី ដើម្បីបញ្ជាក់ពីប្រភេទព័ត៌មានដែលគាត់កំពុងស្វែងរក[59]។

*ការស្តាប់ចម្លើយសាក្សី ជា ម៉ាលី(D36)*

៤៣. ការចោទប្រកាន់អំពីសំណួរនាំមុខដែលចៅក្រម Blunk បានសួរ តាមពិតស្តែងឲ្យឃើញថាជាសម្តីរបស់ចៅក្រម ដែលខ្លឹមសារមិនមានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយឡើយ[60]។

*ការស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន (D76)*

៤៤. មេធាវីការពារក្តី លើកឡើងការតវ៉ាចំនួនពីរទាក់ទងនឹងការស្តាប់ចម្លើយសេង ស្រ៊ុន។

៤៥. យោងតាមមេធាវីការពារក្តី ចៅក្រម Blunk បាននាំមុខ សេង ស្រ៊ុន ដោយសួរគាត់ថាតើគាត់បានកត់សម្គាល់ដែរឬអត់អំពីគំរូឬរបៀបទូទៅទាក់ទងនឹងការសម្លាប់មនុស្សមួយចំនួន[61]។ ដោយពិចារណាលើការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ ខ្ញុំយល់ឃើញថានេះគឺជាសំណួរសមស្រប ដែលមានបំណងបញ្ជាក់ពីលក្ខណៈនៃការសម្លាប់ដែលសាក្សីបានផ្តល់សក្ខីកម្ម។

៤៦. ក្នុងករណីទី ២ ជាដំបូង ចៅក្រម Blunk បានសួរថាតើនរណាជាអ្នកជំនួសឈ្មោះ ស្រេង ក្នុងនាមជាលេខាតំបន់ ហើយ សាក្សីបានឆ្លើយថា គឺឈ្មោះ"*អាន*"[62]។ បន្ទាប់មក ចៅក្រមសួរ

---

[57] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ ស៊ី (D3/11)។។

[58] សំណុំរឿង ០០៤ ឯកសារ D1.3.11.32 *ក.ស.ព ការស្តាប់ចម្លើយ ណៃ ស៊ី* ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៦។

[59] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ និង ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)។

[60] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជា ម៉ាលី (D36)។

[61] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន (D76)។

[62] សំណុំរឿង ០០៤ ឯកសារ D76R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ម៉ោង 00.0៧.៥២-00.0៨.២០។

ថាតើសាក្សីបានដឹងថាតើ អោ អាន មានតួនាទីផ្សេងទៀតដែរឬអត់ ហើយសាក្សីបានឆ្លើយថា គាត់គ្រាន់តែដឹងថា គាត់គឺជា“*គណៈតំបន់*”[63]។ ត្រង់ចំណុចនេះ ចៅក្រម Blunk បានសួរសាក្សី *“តើអ្នកនិយាយថា ឥទ្ធិពល[របស់ អោ អាន] មានច្រើន ឬតិច...តើគាត់បង្ហាញឱ្យឃើញថាជាអ្នកគ្រប់គ្រងពេញលេញដែរឬទេ”*[64]។ នេះក៏ជាសំណួរត្រឹមត្រូវដែរដែលមានបំណងបញ្ជាក់ពីកម្រិតនៃសិទ្ធិអំណាចរបស់ អោ អាន។ បន្ទាប់មក សំណួរនេះបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដាក់ថា “តើឥទ្ធិពល [របស់ អោ អាន] ខ្លាំងប៉ុណ្ណាដែរ?”។ ខ្ញុំមិនឃើញថាមានភាពមិនត្រឹមត្រូវអំពីរបៀបដែលសំណួរនេះបានកត់ត្រាឡើយ។ ខ្ញុំក៏កត់សម្គាល់ថា សាក្សីបានឆ្លើយថា គាត់មិនដឹងថា អោ អាន មានឥទ្ធិពលអ្វីទេ ហេតុនេះ វាច្បាស់គឺថា សាក្សីមិនបានទទួលឥទ្ធិលមិនត្រឹមត្រូវពីសំណួររបស់ចៅក្រម Blunk ទេ[65]។

*ការស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ (D78)*

៤៧. មេធាវីការពារក្តី ចោទថា បន្ទាប់ពីសាក្សីបានបញ្ជាក់ថា អោ អាន គឺជា“គណៈតំបន់ ៤១”មក ចៅក្រម Blunk បានសួរថាតើ អោ អាន គឺជាប្រធាន ឬជាគណៈ ឬគ្រាន់តែជាសមាជិក ហើយសាក្សីឆ្លើយថា គាត់គឺជាប្រធាន[66]។ សំណួរនេះមិនមែនជាសំណួរនាំមុខទេ។ ចៅក្រមបានសួរសាក្សី ឱ្យបញ្ជាក់អំពីតួនាទីរបស់ អោ អាន នៅគណៈតំបន់ ដោយមិនបាននាំមុខសាក្សី ឱ្យផ្តល់ចម្លើយជាក់លាក់ណាមួយឡើយ។ គួរឱ្យចាប់អារម្មណ៍ដែរថា សំណើសុំការបញ្ជាក់បែបនេះជារឿយៗ គឺជាសំណើចាំបាច់ ពីព្រោះថា សាក្សីមាននិន្នាការនិយាយថា ជនណាម្នាក់ជា“គណៈតំបន់” គឺចង់មានន័យថា ជននោះគឺជាប្រធានគណៈតំបន់។ និយាយម្យ៉ាងទៀត សាក្សីមាននិន្នាការចង់បង្ហាញថា ប្រធានគណៈគឺជាគណៈ។ នេះគឺជាករណីកើតឡើងជាធម្មតានៅក្នុងភស្តុតាងដែលទទួលបាននៅក្នុងកិច្ចស៊ើបសួរ[67]។

---

[63] សំណុំរឿង ០០៤ ឯកសារ D76R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ម៉ោង ០០.០៩.៣៣-០០.០៩.៥២។

[64] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន (D76)។

[65] សំណុំរឿង ០០៤ ឯកសារ D76 *កំណត់ហេតុនៃការស្តាប់ចម្លើយ សេង ស្រ៊ុន* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ERN00729734 សំណួរ ៨។

[66] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ (D78)។

[67] *ឧទាហរណ៍* សំណុំរឿង ០០៤ ឯកសារ D219/37 *កំណត់ហេតុនៃការស្តាប់ចម្លើយ សួន មុត* ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ នៅ ERN01032102 សាក្សី បានបញ្ជាក់ថា *“[...]តាមខ្ញុំដឹង យាយចែម ជាសមាជិកគណៈតំបន់[...]”* ហើយ

*ការស្តាប់ចម្លើយសាក្សី ឃុន សារ៉េត (D93)*

៤៨. មេធាវីការពារក្តី លើកឡើងការចោទប្រកាន់ចំនួនបីទាក់ទងនឹងការស្តាប់ចម្លើយសាក្សី ឃុន សេរ៉េត។

៤៩. ចំពោះការចោទប្រកាន់ទី ១ ចៅក្រម Blunk គ្រាន់តែសួរបញ្ជាក់អំពីចម្លើយរបស់សាក្សី ដែលថា ស្ថានភាពរស់នៅ"*លំបាកលំបិន*"។ ចៅក្រមពិតជាបានផ្តល់ឧទាហរណ៍មួយចំនួនដែលប្រហែលជាអាចធ្វើឲ្យមានស្ថានភាពរស់នៅបែបនោះ ប៉ុន្តែ ជួនកាលចាំបាច់ត្រូវធ្វើបែបនេះ ដើម្បីឲ្យសាក្សី យល់សំណួរឲ្យបានត្រឹមត្រូវ[68]។

៥០. ការចោទប្រកាន់ទី ២ ក៏មិនមានមូលដ្ឋានដែរ។ បន្ទាប់ពីសាក្សីបានបញ្ជាក់ថា អោ អាន គឺជាប្រធានតំបន់ ៤១ រហូតដល់ចុងឆ្នាំ ១៩៧៧ ចៅក្រម Blunk បានសួរថាតើសាក្សី ច្បាស់ពីកាលវិច្ឆេទនេះដែរឬអត់ ហើយសាក្សីបានឆ្លើយថា គាត់ច្បាស់[69]។ ខ្ញុំមិនរកឃើញថាមានភាពមិនត្រឹមត្រូវចំពោះសំណួរនេះឡើយ។

៥១. ចំពោះការចោទប្រកាន់ទី បី ចៅក្រម Blunk ព្យាយាមបញ្ជាក់ថាតើ អោ អាន បានមកដល់ជាមួយនឹងកម្មាភិបាលនិរតីផ្សេងទៀតដែរឬអត់។ ខ្ញុំមិនយល់ឃើញថា សំណួរនេះគឺជាសំណួរនាំមុខឡើយ។ ក្នុងករណីណាក៏ដោយ សាក្សី មិនបានយល់សំណួរ ហើយបានបង្ហាញឲ្យឃើញថាហត់អស់កម្លាំងនៅពេលស្តាប់ចម្លើយនៅពេលដល់ចំណុចនេះ។ ហេតុនេះ ការ

---

*"ខ្ញុំបានស្គាល់ និងឃើញគាត់ ដោយសារគាត់បានមកដឹកនាំអង្គប្រជុំ[...]"*។ សំណុំរឿង ០០៤ ឯកសារ D118/77 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣ នៅ ERN00934388 សាក្សីបញ្ជាក់ថា *"[...] ខ្ញុំស្គាល់គណៈតំបន់ឈ្មោះ តា ទិត"*។ ហើយនៅក្នុងចម្លើយឆ្លើយសំណួរថា *"តើលោកស្គាល់ថា តា ទិត ជាគណៈតំបន់ដោយរបៀបណា"* សាក្សីឆ្លើយថា *"ព្រោះតា ទិត គាត់កាន់ក្បាលមេក្រូ ប្រកាសនៅពេលគាត់ប្រជុំជាមួយប្រជាជននៅបាយដំរាំនេះ"*។

[68] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៤.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន សារ៉េត(D93)។

[69] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៥.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន សារ៉េត(D93)។

ស្តាប់ចម្លើយនេះបានបញ្ចប់ ហើយសំណួររបស់ចៅក្រម Blunk ដែលមិនទាន់ទទួលបានចម្លើយផង ក៏កត់ត្រាចូលក្នុងកំណត់ហេតុស្តាប់ចម្លើយ[70]។

*ការស្តាប់ចម្លើយសាក្សី សឹង លឹម (D95)*

៥២. មេធាវីការពារក្តី ចោទថា សំណួរនាំមុខ មិនបានកត់ត្រាឲ្យបានត្រឹមត្រូវទាក់ទងនឹងការស្តាប់ចម្លើយសាក្សី សឹង លឹម ឡើយ[71]។ ចៅក្រម Blunk ដំបូងបានសួរសាក្សីថាតើគាត់ដឹងថាតើអ្នកយាមនៅមន្ទីរសន្តិសុខមកពីណា។ នៅពេលដែលសាក្សីឆ្លើយថា គាត់មិនដឹង ចៅក្រមបានសួរគាត់ថាតើអ្នកយាមទាំងនោះគឺជាអ្នកស្រុក ឬមកពីភូមិភាគនិរតី ហើយសាក្សីបានឆ្លើយថាគាត់មិនដឹង។ កំណត់ហេតុស្តាប់ចម្លើយ សរសេរថា ចៅក្រម Blunk បានសួរថា "*តើអ្នកយាមនៅមន្ទីរសន្តិសុខដែលលោកនិយាយនោះមកពីណាដែរ?*"[72]។ ខ្ញុំចង់បានប្រតិចារឹកដែលកាន់តែដូចគ្នាជាមួយនឹងសម្តីដើម ប៉ុន្តែ របៀបដែលសំណួរនេះបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺត្រឹមត្រូវគ្រប់គ្រាន់ហើយ។

*ការស្តាប់ចម្លើយសាក្សី សេង រុន (D97)*

៥៣. ចំពោះការស្តាប់ចម្លើយសាក្សី សេង រុន មេធាវីការពារក្តី ចោទថា មានករណីចំនួនពីរដែលកំណត់ហេតុស្តាប់ចម្លើយ មិនបានកត់ត្រាលក្ខណៈនៃសំណួរនាំមុខ។

៥៤. នៅក្នុងករណីទី ១ ចៅក្រម Blunk បានសួរសំណួរមួយចំនួនទៅសាក្សី ដោយមានគោលបំណងយ៉ាងច្បាស់ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីស្ថានភាពអ្នកជាប់ឃុំ នៅទីតាំងឧក្រិដ្ឋកម្មមួយកន្លែងដែលបានចោទ[73]។ ខ្ញុំមិនយល់ឃើញថា សំណួរដែលចៅក្រមបានសួរ មានលក្ខណៈបង្អើប ឬក៏មិនត្រឹមត្រូវឡើយ ហើយខ្ញុំជឿជាក់ថា សំណួរដែលបានកត់ត្រានៅក្នុង

---

[70] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៦.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី យុន សារ៉េត(D93)។ សំណុំរឿង ០០៤ ឯកសារ D93R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី យុន សារ៉េត* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ម៉ោង ០០.៣១.៥៧-០០.៣៣.៤៥។

[71] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សឹង លឹម (D95)។

[72] សំណុំរឿង ០០៤ ឯកសារ D95 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង លឹម* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ERN00743588។

[73] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សេង រុន (D97)។

កំណត់ហេតុស្តាប់ចម្លើយ គឺជាសេចក្តីសង្ខេបសមរម្យអំពីសំណួរជាច្រើនដែលចៅក្រម Blunk បានសួរ។

៥៥. នៅក្នុងករណីទី ២ ចៅក្រមបានព្យាយាមបញ្ជាក់អំពីចំនួនអ្នកជាប់ឃុំដែលគេបានសម្លាប់។ មេធាវីការពារក្តី ជំទាស់ទៅនឹងអង្គហេតុដែលថា បន្ទាប់ពីសួរសំណួរនេះ ចៅក្រម Blunk បានបញ្ជាក់ថា *"ហាក់ដូចជាថាអ្នកចាំរឿងនេះ សាក្សីផ្សេងទៀតបានឮថា មនុស្សជាង ៥ 000 នាក់ ត្រូវគេសម្លាប់"*[74]។ ប៉ុន្តែ ចៅក្រម Blunk បាននិយាយឃ្លាចុងក្រោយនេះប្រាប់អ្នកបកប្រែផ្ទាល់មាត់ជាភាសាអង់គ្លេស។ បន្ទាប់មក អ្នកបកប្រែផ្ទាល់មាត់ គ្រាន់តែសួរសាក្សី ជាភាសាខ្មែរថាតើ មានអ្នកទោសប៉ុន្មាននាក់មកពីភូមិភាគបូព៌ាក្នុងចំណោមអ្នកទោសដែលគេសម្លាប់ ដោយមិនបានលើកឡើងពីភស្តុតាងរបស់សាក្សីផ្សេងទៀត ឬបកប្រែអ្វីផ្សេងទៀតនៃសម្តីរបស់ចៅក្រម Blunk ឡើយ[75]។ ជាថ្មីម្តងទៀត នេះគឺជាករណីមួយដែលមេធាវីការពារក្តី បានយកចិត្តទុកដាក់ទាំងខុសលើការប្រាស្រ័យទាក់ទងគ្នាពីអ្នកស៊ើបអង្កេតទៅអ្នកបកប្រែផ្ទាល់មាត់ មិនមែនពីអ្នកបកប្រែផ្ទាល់មាត់ទៅសាក្សីទេ។

*ការស្តាប់ចម្លើយសាក្សី សាន់ សុន (D107/2)*

៥៦. ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី សាន់ សុន ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយនេះ គឺជាសេចក្តីសង្ខេបសមរម្យ និងត្រឹមត្រូវអំពីការឆ្លើយឆ្លងគ្នារវាងអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី[76]។

*ការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)*

៥៧. ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង មេធាវីការពារក្តី បង្ហាញករណីចោទប្រកាន់ចំនួនពីរ ដែលតាមពិត អ្នកស៊ើបអង្កេតមិនបាននិយាយទៅកាន់សាក្សីឡើយ ប៉ុន្តែ

---

[74] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សេង វុន (D97)។

[75] សំណុំរឿង 00៤ ឯកសារ D97R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សីសេង វុន* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ម៉ោង 00.១២.៣0-00.១៤.00។

[76] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សាន់ សុន (D107/2)។

និយាយទៅកាន់អ្នកបកប្រែផ្ទាល់មាត់ ក្នុងគោលបំណងដើម្បីបញ្ជាក់ពីប្រភេទព័ត៌មានដែលគាត់កំពុងស្វែងរកពីសាក្សី[77]។

*ការស្តាប់ចម្លើយសាក្សី មាន សារុធ (D107/9)*

៥៨. ខ្ញុំក៏យល់ឃើញមិនមានមូលដ្ឋានសម្រាប់ការចោទប្រកាន់នានាដែលមេធាវីការពារក្តី បានលើកឡើងដូចខាងក្រោមនេះទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី មាន សារុធ។ ចំពោះការចោទប្រកាន់អំពីការមិនបានកត់ត្រាលក្ខណៈសំណួរនាំមុខ ខ្ញុំបានរកឃើញការពិតថា អ្នកបកប្រែផ្ទាល់មាត់ គ្រាន់តែព្យាយាមបញ្ជាក់អំពីឈ្មោះពេញនៃទីតាំងមួយកន្លែងដែលសាក្សីបានប្រាប់ជាភស្តុតាងរួចហើយ[78]។ ចំពោះការចោទប្រកាន់ថា មានការស្តាប់ចម្លើយពីមុន ហើយមិនបានធ្វើកំណត់ហេតុស្តាប់ចម្លើយនោះ[79] ខ្ញុំបានរកឃើញការពិតថា ការលើកឡើងរបស់អ្នកស៊ើបអង្កេត មិនមែនសំដៅលើការស្តាប់ចម្លើយដែលមិនបានធ្វើកំណត់ហេតុឡើយ ប៉ុន្តែសំដៅលើការចុះដល់ទីកន្លែងជាមួយនឹងសាក្សី ទៅមើលទីតាំងមន្ទីរសន្តិសុខចម្ការស្វាយចន្ទី។ ការចុះដល់ទីកន្លែងនេះ ព្រមទាំងសេចក្តីសង្ខេបអំពីចម្លើយ និងការពន្យល់របស់សាក្សីនៅក្នុងអំឡុងពេលចុះដល់ទីកន្លែងនេះ បានកត់ត្រា នៅក្នុងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ដែលមេធាវីការពារក្តីអាចទទួលបាន[80]។

*ការស្តាប់ចម្លើយសាក្សី ជួង ស្រ៊ីម (D107/10)*

៥៩. ចុងក្រោយ ចំពោះការស្តាប់ចម្លើយ ជួង ស្រ៊ីម អ្នកស៊ើបអង្កេត មិនបាននាំមុខសាក្សីឡើយ។ ប៉ុន្តែ គាត់បានសួរដេញដោលយ៉ាងត្រឹមត្រូវជាមួយសាក្សី អំពីភាពមិនស៊ីសង្វាក់គ្នារវាងចម្លើយដែលទើបតែទទួលបាន ជាមួយនឹងព័ត៌មានដែលសាក្សីបានផ្តល់ឲ្យនៅក្នុងការស្តាប់

[77] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ និង ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)។

[78] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី មាន សារុធ (D107/9)។

[79] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី មាន សារុធ (D107/9)។

[80] សំណុំរឿង ០០៤ ឯកសារ D107/17 *របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង* ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣-៤។

ចម្លើយពីមុនជាមួយនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ព[81]។ សាក្សី បានបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ព នៅដើមដំបូងនៃការស្តាប់ចម្លើយជាមួយនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស[82]។

៦០. ហេតុនេះ នៅក្នុងករណីទាំងអស់ខាងលើ ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយគឺជារបាយការណ៍អាចទុកជឿជាក់បានអំពីលក្ខណៈសំណួរ និងខ្លឹមសារភស្តុតាងដែលបានផ្តល់ឱ្យនៅក្នុងសំណុំរឿង ០០៤ ហើយអនុលោមតាមវិធានស្តីពីការកោសលុបកំណត់ហេតុស្តាប់ចម្លើយនៅ អ.វ.ត.ក។

៦១. ខ្ញុំគ្រាន់តែរកឃើញករណីចំនួនពីរ ដែលកំណត់ហេតុស្តាប់ចម្លើយមិនឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវអំពីការឆ្លើយឆ្លងគ្នារវាងអ្នកស៊ើបអង្កេតជាមួយនឹងសាក្សី។

*ការស្តាប់ចម្លើយសាក្សី ណៃ គឹមសាន់ (D3/14)*

៦២. នៅក្នុងករណីទី ១ មេធាវីការពារក្តី ប្តឹងតវ៉ាថា នៅក្នុងអំឡុងពេលស្តាប់ចម្លើយសាក្សី ណៃ គឹមសាន់ អ្នកស៊ើបអង្កេតបាននាំមុខសាក្សី ស្តីពីថាតើនរណាជាអ្នកជំនួសជនឈ្មោះ តាង ដោយសួរថា *"នៅរយៈពេលនោះ តើ តា អាន ជំនួស តា តាង?"*[83]។ សំណួរនេះគឺជាសំណួរមួយក្នុងចំណោមសំណួរជាច្រើនដែលបានសួរក្នុងគោលបំណងដើម្បីបញ្ជាក់អំពីចម្លើយរបស់សាក្សី ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់តំបន់ ៤១ រវាងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ មានការច្របូកច្របល់ខ្លះរវាងឈ្មោះ "តា អាន" ជាមួយនឹងឈ្មោះ "តា តាង" នៅក្នុងអំឡុងពេលស្តាប់ចម្លើយនោះ ប៉ុន្តែ យ៉ាងហោចណាស់នៅពេលដំបូង អ្នកស៊ើបអង្កេត គួរតែបានព្យាយាមសួរថាតើសាក្សី ស្គាល់នរណាដែលជាអ្នកជំនួស តាង ដែរឬអត់។ ប៉ុន្តែ ដោយពិចារណាលើចម្លើយរបស់សាក្សី ដែលថា គាត់មិនស្គាល់ទេ ប៉ុន្តែ គាត់គ្រាន់តែឮឈ្មោះ

---

[81] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជួង ស្រ៊ីម (D107/10)។ *សូមមើល* សំណុំរឿង ០០៤ ឯកសារ D1.3.11.13 *ក.ស.ព ការស្តាប់ចម្លើយជួង ស្រ៊ីម* ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ERN00766102។

[82] សំណុំរឿង ០០៤ ឯកសារ D107/10 *កំណត់ហេតុនៃការស្តាប់ចម្លើយ ជួង ស្រ៊ីម* ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១២ ERN00784968។

[83] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ គឹមសាន់ (D3/14)។

"អាន" នោះ ទើបបង្ហាញឲ្យឃើញថា សាក្សី មិនបានទទួលរងឥទ្ធិពលមិនត្រឹមត្រូវពីសំណួរនេះឡើយ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីនេះ ព័ត៌មានដែលអ្នកស៊ើបអង្កេតបានផ្តល់ឲ្យគឺបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដូចដែលបានទទួលបានពីសាក្សីដែរ។

៦៣. មេធាវីការពារក្តី ក៏អះអាងថា កំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ គឹមសាន់ បំផ្លើសភស្តុតាងពីព្រោះថា សាក្សីមិនដែលបានបញ្ជាក់ថា អោ អាន ជាអ្នកជំនួស តាង ឡើយ ប៉ុន្តែគ្រាន់តែបានបញ្ជាក់ថា គាត់បានឮឈ្មោះ អោ អាន[84]។ ខ្ញុំមិនយល់ស្របជាមួយនឹងការអះអាងនេះឡើយ ពីព្រោះថា តាមរយៈការឆ្លើយឆ្លងគ្នាពេញលេញរវាងសាក្សី ជាមួយនឹងអ្នកស៊ើបអង្កេត គឺច្បាស់ថា នៅពេលដែគាត់បានបញ្ជាក់ថា "ខ្ញុំឮឈ្មោះ អាន"នោះ គឺសាក្សីសំដៅលើអ្នកជំនួស តាង ហើយ។

*ការស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)*

៦៤. នៅក្នុងករណីទី ២ ចំពោះការស្តាប់ចម្លើយ ដួង ស៊ីម មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ មិនបានកត់ត្រាថា សាក្សីត្រូវបានសួរសំណួរនាំមុខឡើយស្តីពីកាលបរិច្ឆេទនៃការមកដល់របស់កម្មាភិបាលនិរតី និងតួនាទីរបស់ពួកគេនៅក្នុងការចាប់ខ្លួន និងការជំនួសកម្មាភិបាលមូលដ្ឋាន[85]។ មេធាវីការពារក្តី ត្រឹមត្រូវចំពោះចំណុចនេះ។ អ្នកស៊ើបអង្កេត បានផ្តល់ជូនសាក្សី នូវព័ត៌មានអំពីការមកដល់របស់កម្មាភិបាលនិរតី និងតួនាទីរបស់ពួកគេនៅក្នុងការចាប់ខ្លួន ហើយសាក្សីបានបញ្ជាក់អំពីចំណុចទាំងនេះ។ ប៉ុន្តែ ពាក្យពេចន៍នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ បង្ហាញថា សាក្សីផ្តល់ព័ត៌មាននេះដោយស្វ័យភាព[86]។

ii. <u>ការមិនបានកត់ត្រាវត្តមានរបស់ជនមិនស្គាល់អត្តសញ្ញាណ</u>

---

[84] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ណៃ គឹមសាន់ (D3/14)។

[85] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)។

[86] សំណុំរឿង ០០៤ ឯកសារ D3/15 *កំណត់ហេតុនៃការស្តាប់ចម្លើយ ដួង ស៊ីម* ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០ ERN00619830-00619831។

៦៥. មេធាវីការពារក្តី ចោទថាមានវត្តមានរបស់ជនមិនស្គាល់អត្តសញ្ញាណម្នាក់នៅក្នុងការស្តាប់ចម្លើយមួយចំនួនដែលធ្វើឡើងដោយចៅក្រម Blunk[87]។ ប៉ុន្តែ នៅក្នុងករណីទាំងនេះ "មនុស្សមិនស្គាល់អត្តសញ្ញាណ"នោះទំនងជាក្រឡាបញ្ជីឈ្មោះ សោម រតនា ដូចបានកត់សម្គាល់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដែលបានចុះបេសកកម្មជាមួយចៅក្រម Blunk ហើយម្តងម្កាលធ្វើការបញ្ជាក់បំភ្លឺជូនចៅក្រម អំពីសេចក្តីលម្អិតមួយចំនួននៃចម្លើយរបស់សាក្សីណាម្នាក់[88]។

៦៦. មេធាវីការពារក្តី ក៏ធ្វើការចោទប្រកាន់ដូចគ្នានេះចំពោះការស្តាប់ចម្លើយដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតម្នាក់មកពី ក.ស.ច.ស។ ដូចបានពិភាក្សាខាងលើ នៅពេលចុះដល់ទីកន្លែង មិនមែនតែងតែអាចទប់ស្កាត់សាច់ញាតិ និងអ្នកជិតខាង មិនឲ្យនៅជិតកន្លែងស្តាប់ចម្លើយបានឡើយ។ នៅក្នុងឧទាហរណ៍ដែលមេធាវីការពារក្តីបានបង្ហាញការជ្រៀតជ្រែកដែលបានកត់ត្រាទុកវាមិនល្អទេ ប៉ុន្តែមិនបំផ្លាញខ្លឹមសារភស្តុតាងដែលបានកត់ត្រាទុកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយឡើយ[89]។

---

[87] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១, ៤.១, ៥.១, ៦.១ និង ៨.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សួន កានិល (D29)។ ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជា ម៉ាលី (D36)។ ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វ័ន្ន ពៅ (D74)។ ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន សារ៉េត(D93)។

[88] បុគ្គលិករបស់ ក.ស.ច.ស ឈ្មោះ អ៊ីសា ឧស្មាន និង នៅ សុជាតា ត្រូវបានស្នើឲ្យស្តាប់ខ្សែអាត់សំឡេងដើម្បីផ្ទៀងផ្ទាត់ថាតើសំឡេងនោះគឺជាសំឡេងរបស់ សោម រតនា មែនឬទេ ប៉ុន្តែ អ្នកទាំងពីរ បានប្រាប់ថា ពួកគាត់មិនអាចចាំសំឡេងរបស់ សោម រតនា ទេ។ ឆាយ ច័ន្ទលីដា ក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលបានធ្វើការជាមួយនឹង សោម រតនា រយៈពេលយូរជាងគេនៅ ក.ស.ច.ស បានបញ្ជាក់ថា គាត់នឹងអាចស្គាល់សំឡេងរបស់សោម រតនា ប៉ុន្តែ គាត់មិនអាចបញ្ជាក់ថាតើសំឡេងនោះជាសំឡេងរបស់ សោម រតនា ឬអត់នោះទេ ពីព្រោះថានៅពេលដែលស្តាប់ខ្សែអាត់សំឡេងនោះ ជននោះនិយាយពួតិចណាស់នៅក្នុងខ្សែអាត់សំឡេង។

[89] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៣.១, ៣.២, និង ៤.៣ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹម កុល (D107/7)។ ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៣.២ និង ៤.៣ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង (D107/5) វិការៈដែលចោទ ១.២, ៣.១ និង ៤.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី មាស សារុធ (D107/9) និង វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឈុន ឡា (D107/14)។

iii. ការបំប្លែងភស្តុតាង និងការមិនបានកត់ត្រាភស្តុតាងដោះបន្ទុក

៦៧. នៅពេលត្រួតពិនិត្យមើលការចោទប្រកាន់របស់មេធាវីការពារក្តី អំពីការបំប្លែង និងការលុបចោលព័ត៌មាន ខ្ញុំបានរកឃើញថា ក្នុងករណីប៉ុន្មានលើក បញ្ហាបែបនោះគឺជាបញ្ហាតូចតាច ហើយមិនប៉ះពាល់ដល់ខ្លឹមសារភស្តុតាងរបស់សាក្សី ឡើយ។

*ការស្តាប់ចម្លើយសាក្សី វង សុគន្ធ (D107/4)*

៦៨. នៅក្នុងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ បង្ហាញឲ្យឃើញថា សាក្សី ត្រូវបានគេបង្ហាញនូវរូបថតមនុស្សម្នាក់មួយសន្លឹក ហើយត្រូវគេសួរឲ្យកំណត់អត្តសញ្ញាណមនុស្សនោះ។ សាក្សីមិនអាចកំណត់អត្តសញ្ញាណជននោះនៅក្នុងរូបថតបានឡើយ ហើយនៅត្រឹមចំណុចនេះ សាក្សីក៏មិនបានប្រាប់ថាតើជននោះជានរណាដែរ។ ប៉ុន្តែ អ្នកស៊ើបអង្កេតគ្រាន់តែប្រាប់អ្នកធ្វើប្រតិចារឹក ជាភាសាអង់គ្លេស ថា ជននៅក្នុងរូបថតនោះគឺ អោ អាន។ ទោះជាយ៉ាងនេះក្តី កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាថា សាក្សី បញ្ជាក់ថា *"ខ្ញុំមិនស្គាល់ឈ្មោះមនុស្សក្នុងរូបថតនេះទេ [...]។ លោកបានប្រាប់ខ្ញុំថា មនុស្សនេះឈ្មោះ តា អាន ជាលេខាតំបន់៤១"*[90]។ ការឆ្លើយឆ្លងគ្នានេះគួរតែបានកត់ត្រាទុកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយឲ្យបានត្រឹមត្រូវជាងកំណត់សម្គាល់របស់អ្នកស៊ើបអង្កេត ប៉ុន្តែ ពាក្យពេចន៍នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ មិនមានបំណងកត់ត្រាការបញ្ជាក់ពីសាក្សី អំពីថាតើមនុស្សនៅក្នុងរូបថតនោះគឺជា តា អាន ឬក៏មិនមែន តា អាន នោះឡើយ។ ហេតុនេះ ភាពខុសគ្នានេះពិតជាមិនបានបំប្លែងភស្តុតាងរបស់សាក្សី ហើយមិនប៉ះពាល់ដល់ខាងការពារក្តី ដែរ។

*ការស្តាប់ចម្លើយសាក្សី សួន កានិល( D29)*

៦៩. ចំពោះសាក្សី សួន កានិល មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ មិនបានបញ្ចូលចម្លើយរបស់សាក្សី ដែលអាចដោះបន្ទុក នៅក្នុងករណីចំនួនបី។ ក្នុងករណីទី ១ សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលឃើញខ្លឹមសារទូរលេខឡើយ[91]។ ពាក់ព័ន្ធគ្នានេះ កំណត់ហេតុស្តាប់ចម្លើយកត់ត្រាថា សាក្សី និយាយថា គាត់មិនអាចដោះលេខកូដទូរលេខបានឡើយ

[90] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វង សុគន្ធ (D107/4)។

[91] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៥.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សួន កានិល (D29)។

ហើយមិនបានដឹងខ្លឹមសារលិខិតមួយដែលបានបង្ហាញជូនគាត់ នៅក្នុងការស្តាប់ចម្លើយឡើយ[92] ។ មានភាពខុសគ្នាខាងខ្លឹមសាររវាងពាក្យពេចន៍ដែលបាននិយាយនៅក្នុងការស្តាប់ចម្លើយ ជាមួយនឹងពាក្យពេចន៍ដែលបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែ អង្គហេតុដែលថា សាក្សីមិនបានដឹងអំពីខ្លឹមសារទូរលេខ គឺបានសរសេរយ៉ាងត្រឹមត្រូវនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ក្នុងករណីទី ២ ក្រោយមក សួន កានិល ត្រូវបានកត់ត្រាថាបាននិយាយថា "*ការបញ្ជាចាប់មនុស្សគឺមកពីមជ្ឈិម*"[93]។ នេះស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងរបស់សាក្សីនៅក្នុងខ្សែអាត់សំឡេង[94]។ ក្នុងករណីចុងក្រោយ មេធាវីការពារក្តី ចោទថា ការដកចេញពីកំណត់ហេតុស្តាប់ចម្លើយនូវចម្លើយរបស់សាក្សី ដែលថា "*អង្គភាពសន្តិសុខ*"ដែលឲ្យបញ្ជាចាប់មនុស្ស គឺជាអង្គហេតុ"*មិនងាយយល់*"នោះ គឺជាការដកចេញនូវភស្តុតាងពាក់ព័ន្ធ និងដោះបន្ទុក[95]។ អង្គហេតុដែលថា ចម្លើយនេះបានដកចេញពីកំណត់ហេតុស្តាប់ចម្លើយគឺមិនសំខាន់ឡើយ ពីព្រោះថា សាក្សីបញ្ជាក់ថែមទៀតថា គាត់បានដឹងអំពី"អង្គភាពសន្តិសុខ" ដោយសារការងាររបស់គាត់។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)*

៧០. មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ ដកចេញសេចក្តីលម្អិតនៃភស្តុតាងរបស់សាក្សី ទាក់ទងនឹង អោ អាន ចុះទៅជួប យាយ យុត និងការឃើញតាអាន ដោយផ្ទាល់ខ្លួន[96]។ ប៉ុន្តែ ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយ ផ្តល់សេចក្តីសង្ខេបយ៉ាងត្រឹមត្រូវអំពីភស្តុតាងពាក់ព័ន្ធនានារបស់សាក្សី ស្តីពីបញ្ហាទាំងនោះ[97]។ ជាងនេះទៀត មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ មិនបានទទួលស្គាល់ព័ត៌មានដែលជនមិនស្គាល់អត្តសញ្ញាណម្នាក់

---

[92] សំណុំរឿង ០០៤ ឯកសារ D29 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១១ ERN00705153។

[93] ដូចជើងទំព័រខាងលើ ERN00705154។

[94] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៧.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សួន កានិល (D29)។

[95] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៨.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សួន កានិល (D29)។

[96] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៤.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7) ។

[97] សំណុំរឿង ០០៤ ឯកសារ D107/7 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល* ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00784981។

បានផ្តល់ឲ្យនៅក្នុងអំឡុងពេលស្តាប់ចម្លើយ[98]។ មិនល្អឡើយដែលជននោះមានវត្តមាននៅក្នុងអំឡុងពេលស្តាប់ចម្លើយ ហើយអត្តសញ្ញាណរបស់គាត់ មិនបានកត់ត្រាទុកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ប៉ុន្តែ តាមរយៈខ្សែអាត់សំឡេងទាំងស្រុង គឺច្បាស់ថា មិនមានឃើញពីផលប៉ះពាល់ដោយសារមតិយោបល់របស់ជននោះមកលើភស្តុតាងរបស់សាក្សីឡើយ។ សាក្សីបានផ្តល់ភស្តុតាងយ៉ាងលម្អិត និងដោយឯករាជ្យទៅលើបញ្ហាដែលជនមិនស្គាល់អត្តសញ្ញាណនោះបានផ្តល់មតិយោបល់។

៧១. មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹម កុល ក៏បំផ្លើសភស្តុតាងរបស់គាត់ដែរ ត្រង់ចំណុចដែលសរសេរថា មនុស្ស“*ទាំងអស់*”ដែលធ្វើការចាប់ខ្លួនតាមបញ្ជារបស់ យាយ យុត គឺមកពីភូមិភាគនិរតី ដោយសារថា នៅក្នុងការស្តាប់ចម្លើយ សាក្សីបាននិយាយថា “*ច្រើនតែមកពីនិរតីទាំងអស់*”[99]។ ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយស៊ីសង្វាក់យ៉ាងខ្លាំងជាមួយនឹងភស្តុតាងរបស់សាក្សី ដោយពិនិត្យឃើញថា គាត់ក៏បានបញ្ជាក់ពីមុនរួចហើយនៅក្នុងការស្តាប់ចម្លើយថា *“គាត់ចង់ចាប់អ្នកណាមួយ គឺគាត់បញ្ជាទៅ។ តែបក្សពួកគាត់ហ្នឹងដែលមកពីនិរតីទាំងអស់ ពីព្រោះ ពួកយើងគាត់អត់ទាន់ទុកចិត្តប៉ុន្មានទេ។ បាទ អញ្ចឹង គាត់ឲ្យពួកហ្នឹងទៅទាំងអស់”*[100]។

៧២. កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ដែលធ្វើឡើងនៅពេលក្រោយមក មានចម្លើយទាក់ទងនឹងបញ្ហានេះគឺថា តំបន់ មិនធ្វើការចាប់មនុស្សដោយខ្លួនឯងឡើយ។ ការចាប់មនុស្សគឺធ្វើឡើងដោយស្រុក និងឃុំ ហើយបន្ទាប់មក ជាអ្នកបញ្ជូនអ្នកដែលគេចាប់ខ្លួនទៅតំបន់[101]។ មេធាវីការពារក្តី ចោទថា ភស្តុតាងបែបនេះមិនស៊ីគ្នាជាមួយនឹងខ្សែអាត់សំឡេងដែលសាក្សីបានបញ្ជាក់ថា តំបន់មិនបានធ្វើអ្វីឡើយទាក់ទងនឹងការចាប់មនុស្ស[102]។ ចំណុចនេះមិនត្រឹមត្រូវឡើយ ពីព្រោះថា សាក្សី បានបញ្ជាក់នៅក្នុងអំឡុងពេលស្តាប់ចម្លើយថា បន្ទាប់ពីចាប់មនុស្ស

---

[98] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៤.៣ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹម កុល (D107/7)។

[99] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៦.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹម កុល (D107/7)។

[100] សំណុំរឿង០០៤ ឯកសារ D219/422.5 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញ៉ឹម កុល ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២* ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៥ ERN01121177។

[101] សំណុំរឿង ០០៤ ឯកសារ D107/8 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹម កុល* ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00784985-0078986។

[102] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៩.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹម កុល (D107/8)។

01312330



ស្រុកបញ្ជូនអ្នកដែលគេចាប់ទៅតំបន់ ដែលនេះហាក់បង្ហាញថា យ៉ាងហោចណាស់ តំបន់មានតួនាទីមួយនៅក្នុងដំណើរការពាក់ព័ន្ធនឹងអ្នកទោសដែលស្រុកបញ្ជូនមក។ សាក្សីក៏បានបញ្ជាក់ថា គាត់មិនដឹងថាតើតំបន់បានចេញបញ្ជាទាក់ទងនឹងការចាប់មនុស្សដែរឬនោះឡើយ គឺមិនដូចការលើកឡើងរបស់មេធាវីការពារក្តី ដែលថា តំបន់គ្មានអ្វីពាក់ព័ន្ធនឹងការចាប់មនុស្សឡើយ[103]។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)*

៧៣. ការចោទប្រកាន់ចំនួនពីរបន្ថែមទៀតអំពីការបំប្លែងភស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយ ញឹម កុល ដែលបានធ្វើឡើងនៅពេលមកទៀត គឺជាការចោទប្រកាន់គ្មានមូលដ្ឋាន។ ចំពោះការចោទប្រកាន់ទី ១ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាយ៉ាងត្រឹមត្រូវថា សាក្សីមិនបានដឹងច្រើនអំពីភ្នំប្រុស ឡើយ[104]។ ចំពោះការចោទប្រកាន់ទី ២ កំណត់ហេតុស្តាប់ចម្លើយ បានសង្ខេបយ៉ាងសមរម្យអំពីភស្តុតាងរបស់សាក្សី ស្តីពីការបង្កើតមន្ទីរសន្តិសុខតំបន់នៅពេលដែល តា អាន មកដល់[105]។

*ការស្តាប់ចម្លើយសាក្សី នីវ ស៊ុន (D3/10)*

៧៤. មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ នីវ ស៊ុន មិនបានបញ្ចូលចម្លើយរបស់គាត់ដែលថា គាត់មិនចាំរចនាសម្ព័ន្ធអំណាចបានច្បាស់ឡើយ ពីព្រោះថា គាត់នៅក្មេងពេកនៅពេលនោះ។ មេធាវីការពារក្តី អះអាងថា ព័ត៌មានដែលលុបចោលនេះគឺពាក់ព័ន្ធនឹងការវាយតម្លៃលើសាក្សី[106]។ មិនល្អឡើយដែលចម្លើយបែបនេះបានដកចេញពីកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែថ្ងៃខែឆ្នាំកំណើតរបស់គាត់ មានសរសេរកត់សម្គាល់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ហេតុនេះ អង្គហេតុដែលថា គាត់មានអាយុ ៥ ឆ្នាំ នៅឆ្នាំ ១៩៧៥ គឺបង្ហាញឲ្យឃើញភ្លាមៗ ហើយ

---

[103] សំណុំរឿង០០៤ ឯកសារ D219/422.4 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២* ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៥ ERN01121083។

[104] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)។

[105] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)។

[106] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី នីវ ស៊ុន (D3/10)។

មានឥទ្ធិពលមកលើអ្នកអានក្នុងការវាយតម្លៃភាពអាចទុកចិត្តបាននៃភស្តុតាងនេះ[107]។ ហេតុនេះ ការលុបចោលព័ត៌មាននេះ មិនប៉ះពាល់ដល់លទ្ធភាពរបស់ ស.ច.ស ក្នុងការថ្លឹងថ្លែងយ៉ាងត្រឹមត្រូវទៅលើភស្តុតាងរបស់សាក្សីរូបនេះឡើយ។

*ការស្តាប់ចម្លើយសាក្សី វ័ត្ត ពៅ (D74)*

៧៥. ចំពោះភស្តុតាងរបស់សាក្សី វ័ត្ត ពៅ ការលុបចោលចម្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលថា ពួកភូមិភាគនិរតី"ប្រហែលជាមកដល់នៅចុងខែ មិថុនា ឆ្នាំ ១៩៧៧" គឺមិនពាក់ព័ន្ធឡើយ ពីព្រោះថា សាក្សីបានបន្ថែមថា គាត់គ្រាន់តែស្មានប៉ុណ្ណោះ[108]។ កំណត់ហេតុស្តាប់ចម្លើយ បង្ហាញយ៉ាងត្រឹមត្រូវអំពីមន្ទិលរបស់សាក្សី ចំពោះចំណុចនេះ[109]។

*ការស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ (D78)*

៧៦. ចំពោះកំណត់ហេតុស្តាប់ចម្លើយ ជីន ស៊ីណាល់ ការព្រួយបារម្ភរបស់មេធាវីការពារក្តី ដែលថា កំណត់ហេតុស្តាប់ចម្លើយ បំផ្លើសភស្តុតាង គឺជាការព្រួយបារម្ភគ្មានមូលដ្ឋាន ពីព្រោះថា កំណត់ហេតុស្តាប់ចម្លើយ ស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងរបស់សាក្សី ចំពោះតួនាទីរបស់ អោ អាន នៅតំបន់ ហើយការចូលរួមរបស់គាត់នៅទំនប់តំបន់មួយកន្លែង សម្រាប់កិច្ចប្រជុំប្រចាំខែ[110]។ ខ្ញុំក៏ជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយ ផ្តល់សេចក្តីសង្ខេបយ៉ាងត្រឹមត្រូវអំពីភស្តុតាងរបស់សាក្សី ហើយមិនបានព្យាយាមកែចម្លើយឱ្យកាន់តែស៊ីសង្វាក់គ្នា ដោយមិនត្រឹមត្រូវឡើយ[111]។

---

[107] សំណុំរឿង ០០៤ ឯកសារ D3/10 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១០ ERN00619845។

[108] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វ័ត្ត ពៅ (D74)។

[109] សំណុំរឿង ០០៤ ឯកសារ D74 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ័ត្ត ពៅ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ERN00729728។

[110] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ (D78)។

[111] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ (D78)។

*ការស្តាប់ចម្លើយសាក្សី យុន សារ៉េត (D93)*

៧៧. ចំពោះសាក្សី យុន សារ៉េត ភស្តុតាងរបស់សាក្សីរូបនេះដែលថា តា អាន ជាគណៈតំបន់ចាប់ពី "*ឆ្នាំ ១៩៧៦...ដល់ឆ្នាំ ១៩៧៧*" បានកត់ត្រាទុកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយថា "*ពីចុងឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧*" ដែលមេធាវីការពារក្តី ចោទថាគឺជាបំផ្លើសភស្តុតាង ដើម្បីបង្ហាញឲ្យកាន់តែឃើញថាជាភស្តុតាងដាក់បន្ទុក[112]។ ខ្ញុំយល់ឃើញថា ភាពខុសគ្នានេះមិនសំខាន់ទេពីព្រោះថា ចម្លើយរបស់សាក្សីទាំងនៅក្នុងខ្សែអាត់សំឡេង ទាំងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺជាការប៉ាន់ស្មានទូទៅ[113]។

*ការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)*

៧៨. មេធាវីការពារក្តី តវ៉ាថា កំណត់ហេតុស្តាប់ចម្លើយ មិនបានប្រើប្រាស់ភាសារបស់សាក្សី នៅក្នុងខ្សែអាត់សំឡេងដែលថា ប្រាក់ យុត ទទួលបន្ទុក "បោសសម្អាត" ប៉ុន្តែបែរជាកត់ត្រាសម្តីសាក្សី ថា គាត់ទទួលខុសត្រូវ"ចាប់មនុស្ស"[114]។ ដោយអានកំណត់ហេតុស្តាប់ចម្លើយទាំងស្រុង គឺឃើញយ៉ាងច្បាស់ថា ការបោសសម្អាតដែលសាក្សី បាននិយាយគឺពាក់ព័ន្ធនឹងការចាប់មនុស្ស និងវិធានការបង្ខំផ្សេងទៀត (ឧទាហរណ៍ សាក្សីបានបញ្ជាក់ថា *កម្លាំងសន្តិសុខ* ទទួលបន្ទុកការបោសសម្អាត ហើយមនុស្សពីរនាក់បានគេចផុតពីការចាប់ខ្លួនរបស់ យាយ យុត)[115]។ ហេតុនេះ ពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ចាប់ខ្លឹមសារបានត្រឹមត្រូវគ្រប់គ្រាន់អំពីលក្ខណៈនៃភស្តុតាងរបស់សាក្សី។

៧៩. ជាងនេះទៀត មេធាវីការពារក្តី ចោទថា ភស្តុតាងដែលអាចដោះបន្ទុកស្តីពីការដឹងឮរបស់សាក្សី អំពី អោ អាន បានដកចេញពីកំណត់ហេតុស្តាប់ចម្លើយ រួមមាន "*តា អាន ជាប្តី យាយ យុត*" ហើយនៅពេលគេបង្ហាញរូបថត អោ អាន មួយសន្លឹក គាត់និយាយថា "*ខ្ញុំមិនដែលឃើញគាត់*"[116]។ ដោយបានត្រួតពិនិត្យកំណត់ហេតុស្តាប់ចម្លើយ ធៀបជាមួយនឹងខ្សែអាត់

---

[112] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី យុន សារ៉េត (D93)។

[113] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ២.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី យុន សារ៉េត (D93)។

[114] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)។

[115] សំណុំរឿង ០០៤ ឯកសារ D107/5 *កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ិន គឹមអេង* ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

[116] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៤.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)។

សំឡេង ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយ សង្ខេបយ៉ាងត្រឹមត្រូវអំពីព័ត៌មានពាក់ព័ន្ធ ដែលសាក្សី បានផ្តល់ឲ្យទាក់ទងនឹងការដឹងឮរបស់គាត់ អំពី អោ អាន។ ចំពោះសម្តីរបស់អ្នកបកប្រែផ្ទាល់មាត់ ដែលប្រាប់សាក្សី ថា យាយ យុត មិនមែនជាប្តីរបស់ អោ អាន ទេ គឺជាអ្វីមិនគួរធ្វើឡើង ប៉ុន្តែនៅក្នុងបរិបទនោះ គឺជាសម្តីមិនគ្រោះថ្នាក់ដែលប៉ះពាល់ដល់ភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយឡើយ[117]។

*ការស្តាប់ចម្លើយសាក្សី មាន សារុធ (D107/9)*

៨០. មេធាវីការពារក្តី ចោទថា កំណត់ហេតុស្តាប់ចម្លើយ បំផ្លើសជំនឿចិត្តរបស់សាក្សី ចំពោះបញ្ហាមួយ ដោយមិនបានកត់ត្រាចម្លើយរបស់សាក្សី នៅក្នុងខ្សែអាត់សំឡេងដែលថា គាត់មិនច្បាស់អំពីបញ្ហានោះឡើយ[118]។ ចម្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ចាប់ផ្តើមសរសេរដោយពាក្យថា *"តាមខ្ញុំដឹង ខ្ញុំគិតថា [...]"*ដែលនេះបង្ហាញគ្រប់គ្រាន់ អំពីកម្រិត មិន ច្បាស់ របស់សាក្សី ចំពោះបញ្ហាដែលគេចោទសួរគាត់។

*ការស្តាប់ចម្លើយសាក្សី បាន សៀក (D107/15)*

៨១. សាក្សី បាន សៀក ផ្តល់ភស្តុតាងថា នៅពេល កែ ពក មិននៅកន្លែង ឬក៏ចុះបេសកកម្មនៅក្រៅភូមិភាគរបស់គាត់ អនុគាត់ ដូចជា ស៊ឹម, អឿន និង អោ អាន មិនបានជំនួសគាត់ឡើយ ពីព្រោះថា ពួកគាត់ទទួលបន្ទុកស្រុក។ ចម្លើយផ្នែកនេះមិនបានបញ្ចូលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទេ ដោយកំណត់ហេតុនេះគ្រាន់តែលើកឡើងវិញអំពីភស្តុតាងរបស់សាក្សីដែលថា ប្រធានមន្ទីររបស់កែ ពក គឺជាមនុស្សម្នាក់គត់ដែលអាចជំនួសគាត់នៅពេលដែលគាត់មិននៅ។ មិនមានភាពខុសគ្នាធ្ងន់ធ្ងរវាងចម្លើយនេះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ជាមួយនឹងខ្សែអាត់សំឡេង ដូចដែលមេធាវីការពារក្តី បានចោទឡើយ[119]។

### iv. <u>ការលុបចោល និងភាពខុសគ្នាដែលមានលក្ខណៈកាន់តែធ្ងន់ធ្ងរ</u>

---

[117] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៤.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (D107/5)។

[118] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៥.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី មាន សារុធ (D107/9)។

[119] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៨.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី បាន សៀក (D107/15)។

៨២. ប៉ុន្តែ ការវិភាគរបស់ខ្ញុំទៅលើការបំប្លែង និងការលុបចោលដែលបានចោទ បានរកឃើញករណីមួយចំនួនដែលការលុបចោល និងភាពខុសគ្នាមានលក្ខណៈរហូតដល់ប៉ះពាល់ភស្តុតាងរបស់សាក្សី ទោះបីជាប៉ះពាល់ក្នុងកម្រិតផ្សេងគ្នាយ៉ាងណាក៏ដោយ។ ខ្ញុំនឹងដោះស្រាយករណីនីមួយៗដូចខាងក្រោម។

*ការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១០ (D13/19)*

៨៣. យោងតាមប្រតិចារឹកនៃខ្សែអាត់សំឡេង វង សុគន្ធ បានបញ្ជាក់ថា កែ ពក គឺជាសមាជិកតែម្នាក់គត់នៃគណៈភូមិភាគ(កណ្តាល)។ ប៉ុន្តែ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ សរសេរថា កែ ពក គឺជា"*លេខាភូមិភាគ*" ជាការលើកឡើងដែលមិនបានក្តោបខ្លឹមសារដែលថា បើតាមសាក្សី កែ ពក គឺជាសមាជិក*ម្នាក់គត់*នៅគណៈភូមិភាគ[120]។

*ការស្តាប់ចម្លើយ វង សុគន្ធ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (D107/4)*

៨៤. នៅក្នុងការស្តាប់ចម្លើយនេះ វង សុគន្ធ បានបញ្ជាក់ថា ឪពុកគាត់ត្រូវគេចាប់ខ្លួននៅឆ្នាំ ១៩៧៦។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយ សរសេរថា ឪពុករបស់សាក្សី ត្រូវគេ ចាប់ខ្លួននៅឆ្នាំ ១៩៧៧[121]។ នេះគឺជាកំហុសជាក់ស្តែងដែលបំប្លែងភស្តុតាងរបស់ វង សុគន្ធ។

៨៥. ប៉ុន្តែ ប្រសិនបើពិចារណាលើបរិបទនៃការស្តាប់ចម្លើយទាំងមូល កំហុសឆ្គងនេះមានផលប៉ះពាល់តិចតួចមកលើភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយ៖ នៅក្នុងអំឡុងពេលស្តាប់ចម្លើយ សាក្សីរូបនេះបានប្រាប់ពេលវេលាថែមទៀត និងកាន់តែអាចជឿជាក់បានទាក់ទងនឹងការចាប់ខ្លួនឪពុកគាត់ ដូចជា ថា ការចាប់ខ្លួននេះបានធ្វើឡើងបន្ទាប់ពីកម្មាភិបាលនិរតី និងយាយ យុត មកដល់តំបន់ ៤១ ភូមិភាគកណ្តាល[122]។

---

[120] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៩.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វង សុគន្ធ (D3/19)។

[121] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១០.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី វង សុគន្ធ (D107/4)។

[122] សំណុំរឿង ០០៤ ឯកសារ D107/4 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ* ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00785001។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (D107/7)*

៨៦. នៅក្នុងការស្តាប់ចម្លើយនេះ ញឹម កុល បានបញ្ជាក់ថា គាត់គ្រាន់តែធ្លាប់ឃើញ អោ អាន ម្តង នៅការដ្ឋានមួយកន្លែង។ សាក្សីក៏បានបញ្ជាក់ថា នៅពេលនោះ គាត់ឃើញ អោ អាន ពីក្រោយខ្នង ដែលនេះជាព័ត៌មានលម្អិតមួយពាក់ព័ន្ធនឹងភាពអាចជឿជាក់បាននៃការបញ្ជាក់អត្តសញ្ញាណពីសាក្សី។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយ មិនមានព័ត៌មាននេះឡើយ[123]។

៨៧. នៅក្នុងការស្តាប់ចម្លើយដដែលនេះដែរ បន្ទាប់ពីបានបញ្ជាក់ថា យាយ យុត មាន"អំណាចពេញលេញ"ដើម្បីចាប់មនុស្សរួចមក សាក្សីបានបញ្ជាក់ថា *"យើងដឹងតាមគ្នាថា បើគេចាប់នរណាម្នាក់ គាត់មិនរាយការណ៍ទៅថ្នាក់លើទេ។ គាត់ធ្វើខ្លួនឯង"*។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយ គ្រាន់តែកត់ត្រាថា យាយ យុត *"យាយ យុត មានអំណាចពេញលេញកាន់កាប់ស្រុកទាំងមូល ហើយនិងសម្រេចចង់ឱ្យអ្នកណាស្លាប់ ឬរស់"*។ អង្គហេតុដែលថា គាត់មានស្វ័យភាពក្នុងការសម្រេចលើការចាប់មនុស្ស បានកត់ត្រាទុក[124] ប៉ុន្តែ ចម្លើយរបស់សាក្សីដែលថា ព័ត៌មានស្តីពីចាប់ខ្លួនមិនបានរាយាការណ៍ទៅថ្នាក់លើទេ គឺមិនមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយទេ[125]។

៨៨. ប៉ុន្តែ សាក្សី ក៏បានបញ្ជាក់ថា កម្មាភិបាលមួយចំនួនដែលគេចាប់ខ្លួន បានបញ្ជូនទៅតំបន់ ហើយមិនត្រូវបានសម្លាប់នៅថ្នាក់ស្រុកទេ[126]។ ជាងនេះទៀត សាក្សីបានបញ្ជាក់ថា គាត់មិនដែលឃើញនរណារាយការណ៍ទៅ អោ អាន ដោយផ្ទាល់ទេ ប៉ុន្តែ គាត់មិនដឹងថាតើ អោ អាន បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរដែរឬទេ[127]។ ចម្លើយទាំងពីរនេះគឺពាក់ព័ន្ធ និងផ្តល់គុណវុឌ្ឍិទៅចម្លើយពីមុនរបស់សាក្សី ដែលថា ការចាប់ខ្លួនមិនបានរាយការណ៍ទៅថ្នាក់លើទេ៖ ទី ១ ប្រសិនបើកម្មាភិបាលមួយចំនួនដែលគេចាប់ខ្លួនបានបញ្ជូនទៅតំបន់ តំបន់បាន

---

[123] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៤.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។

[124] *សូមមើលផងដែរ* ERN00784983 ឯកសារ D107/7។

[125] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៥.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។ *សូមមើល* សំណុំរឿង ០០៤ ឯកសារ D107/7 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល* ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00784983។

[126] សំណុំរឿង០០៤ ឯកសារ D219/422.5 *ប្រតិចារិកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01121178។

[127] សំណុំរឿង០០៤ ឯកសារD219/422.4 *ប្រតិចារិកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01121085។

ដឹងយ៉ាងហោចណាស់អំពីការចាប់ខ្លួនមួយចំនួនក្នុងចំណោមការចាប់ខ្លួនទាំងនោះ។ ទី ២ ប្រសិនបើសាក្សីអាចបញ្ជាក់ថា ការចាប់ខ្លួនបានរាយការណ៍ជាលាយលក្ខណ៍អក្សរទៅ អោ អាន វិញ គឺគាត់មិនស្ថិតនៅក្នុងតួនាទីមួយអាចបញ្ជាក់បានថា យាយ យុត មិនបានរាយការណ៍អំពីការចាប់ខ្លួនទៅថ្នាក់លើទេ។ ហេតុនេះ ព័ត៌មានដែលបានលុបចោល គួរតែបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែ ខ្ញុំមិនយល់ឃើញថា ការលុបចោលព័ត៌មាននេះ បំភាន់ខ្លឹមសារភស្តុតាងរបស់គាត់ឡើយ។

៨៩. នៅក្នុងការស្តាប់ចម្លើយដដែលនេះ ទាក់ទងនឹងការចាប់ខ្លួន សាក្សីបានបញ្ជាក់ថា *"ខ្មែរក្រហមនៅពេលនោះ ហាក់ដូចជាមិនទទួលបញ្ជាពីថ្នាក់លើឡើយ"*។ ព័ត៌មាននេះមិនមានសរសេរនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ[128]។ ប៉ុន្តែ បន្ទាប់ពីសាក្សីបាននិយាយបែបនេះហើយ អ្នកស៊ើបអង្កេត មានកាតព្វកិច្ចត្រូវស្វែងរកប្រធានបទនេះ ដោយសួរថាតើ យាយ យុត បានចាប់មនុស្ស ដោយចេញពីគំនិតខ្លួនឯង ឬក៏តាមបញ្ជាពីតំបន់ ឬភូមិភាគ។ សាក្សីបានឆ្លើយថា មិនមានបញ្ជាពីថ្នាក់លើទេ ហើយ យាយ យុត អាចធ្វើការសម្រេចដោយខ្លួនឯង[129]។ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាព័ត៌មាននេះយ៉ាងត្រឹមត្រូវ ដោយបញ្ជាក់ថា សាក្សីគិតថា ចំពោះ យាយ យុត *"ការចាប់គឺសម្រេចខ្លួនគាត់ផ្ទាល់"* [130]។ ចំពោះប្រយោគចុងក្រោយនេះ មេធាវីការពារក្តី ប្តឹងថា សាក្សីមិនបានស្រពិចស្រពិលទេនៅក្នុងចម្លើយរបស់គាត់ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាថា សាក្សី បញ្ជាក់ថា *"ខ្ញុំ<u>គិត</u>ថា ការចាប់គឺសម្រេចខ្លួនគាត់ផ្ទាល់"*[131]។ ជាការល្អគឺថា កម្រិតនៃភាពច្បាស់លាស់ដែលសាក្សីបានបង្ហាញក្នុងការឆ្លើយសំណួរ គួរបានឆ្លុះបញ្ចាំងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែ នៅក្នុងការវាយតម្លៃទម្ងន់ និងតម្លៃភស្តុតាងនេះ និងភស្តុងតាងផ្សេងទៀត ខ្ញុំនឹងពិចារណាលើមូលដ្ឋានចំណេះដឹងរបស់សាក្សី ដោយផ្អែកលើព័ត៌មានទាំងស្រុងដែលសាក្សីនោះបានផ្តល់ឲ្យនៅក្នុងអំឡុងពេលស្តាប់ចម្លើយ។

*ការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ (D107/8)*

---

[128] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៧.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។

[129] សំណុំរឿង០០៤ ឯកសារ D219/422.5 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01121180។

[130] *សូមមើល* ERN00784983 ឯកសារ D107/7។

[131] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ៨.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/7)។

៩០. ចំពោះការស្តាប់ចម្លើយនេះ មេធាវីការពារក្តី មានការជំទាស់ផ្សេងៗ ដូចជា ការចោទប្រកាន់អំពីការលុបចោលពីកំណត់ហេតុស្តាប់ចម្លើយនូវភស្តុតាងដែលថា តំបន់មិនបានបញ្ជាថ្នាក់ស្រុក ឲ្យចាប់មនុស្ស ហើយសាក្សីមិនដែលឃើញ អោ អាន នៅក្នុងកិច្ចប្រជុំតំបន់ឡើយ ឬក៏ឃើញនរណារាយការណ៍ទៅ អោ អាន ដោយផ្ទាល់ទាក់ទងនឹងការចាប់មនុស្សឡើយ[132]។ ប៉ុន្តែ ដូចបានកត់សម្គាល់ខាងលើទាក់ទងនឹង D107/7 សាក្សីក៏បានបញ្ជាក់ថា គាត់មិនបានដឹងថាតើ អោ អាន បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរឬអត់នោះឡើយ[133]។ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាការឆ្លើយឆ្លងគ្នាដូចខាងក្រោម៖

*ស៖ តើថ្នាក់ស្រុកមានដែលទទួលបញ្ជាពីថ្នាក់តំបន់ទេ?*

*ឆ៖ ខ្ញុំមិនដឹងទេ ប៉ុន្តែ ប្រហែលជាស្រុក ទទួលបញ្ជាពីតំបន់ជាលាយលក្ខណ៍អក្សរដែលខ្ញុំពុំអាចដឹងបាន*[134] ។

៩១. អង្គហេតុដែលថា សាក្សី មិនបានឃើញ អោ អាន ទទួលរបាយការណ៍ទាក់ទងនឹងការចាប់ខ្លួននោះ គឺមិនមែនទាត់ចោលលទ្ធភាពដែលថា គាត់អាចទទួលរបាយការណ៍បែបនោះឡើយ។ ជាងនេះទៀត សាក្សីបានបញ្ជាក់ថា គាត់មិនស្ថិតនៅក្នុងតួនាទីដែលអាចដឹងអំពីរបាយការណ៍ជាលាយលក្ខណ៍អក្សរឡើយ។ ហេតុនេះ ភស្តុតាងអាចសង្ខេបជាទូទៅឲ្យខ្លីនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ តែ ខ្ញុំជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីអង្គហេតុដែលថា សាក្សីមិនស្ថិតនៅក្នុងតួនាទីអាចដឹងថាតើ អោ អាន បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ជាចាប់មនុស្ស ឬអត់នោះទេ។

៩២. មេធាវីការពារក្តី ក៏ចង្អុលបង្ហាញថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ សាក្សី ត្រូវបានកត់ត្រាថាបានបញ្ជាក់ថា ភ្នំប្រុស គឺជាមន្ទីរសន្តិសុខថ្នាក់តំបន់ ប៉ុន្តែ តាមពិត សាក្សីបានបញ្ជាក់ថា ភ្នំប្រុស គឺជាមន្ទីរសន្តិសុខភូមិភាគ[135]។ មេធាវីការពារក្តី ត្រឹមត្រូវ។ កំណត់ហេតុស្តាប់

---

[132] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១០.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)។

[133] សំណុំរឿង004 ឯកសារ D219/422.4 *ប្រតិចារឹកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ញឹម កុល* ERN01121085។

[134] សំណុំរឿង ០០៤ ឯកសារ D107/8 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល* ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00784986។

[135] ឧបសម្ព័ន្ធ ក វិការៈដែលចោទ ១១.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ញឹម កុល (D107/8)។

ចម្លើយ មានកំហុសឆ្គងជាក់ស្តែងនៅក្នុងសំណៅដើមជាភាសាខ្មែរ[136]។ ប៉ុន្តែ ខ្ញុំកត់សម្គាល់ថា នៅក្នុងចម្លើយបន្ទាប់ មានកំណត់ហេតុយ៉ាងត្រឹមត្រូវថា សាក្សីបានបញ្ជាក់ថា "ជឿន"គឺជាប្រធានសន្តិសុខ*ភូមិភាគ*នៅភ្នំប្រុស[137]។ ហេតុនេះ ឋានៈ ភ្នំប្រុស ជាមន្ទីរសន្តិសុខតំបន់ ប្រាកដជាកើតឡើងដោយសារកំហុសក្រឡាបញ្ជីដែលមិនគួរកើតឡើង។

*ការស្តាប់ចម្លើយសាក្សី ដួង ស៊ីម ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០ (D3/15)*

៩៣. មេធាវីការពារក្តី ប្តឹងថា សាក្សីបានបញ្ជាក់ថា គាត់មិនច្បាស់អំពីតួនាទីរបស់ អោ អាន ឡើយ ប៉ុន្តែ ព័ត៌មាននេះមិនបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ឡើយ[138]។ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាថា សាក្សីបានបញ្ជាក់ថា គាត់ *"បានឮឈ្មោះមិត្ត អាន ប្រធានគណៈតំបន់"* ប៉ុន្តែ គាត់មិនដែលបានជួប អោ អាន ទេ[139]។ ខ្ញុំយល់ស្របតាមមេធាវីការពារក្តី ដែលថា សម្តីរបស់សាក្សី ដែលថា គាត់មិនច្បាស់អំពីតួនាទីរបស់ អោ អាន គួរតែបានកត់ត្រាឲ្យបានច្បាស់ជាងនេះ។ ប៉ុន្តែ ខ្ញុំកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយ ពិតជាកត់ត្រាថា សាក្សី "បានឮ"ឈ្មោះ អោ អាន ហើយគាត់មិនដែលបានជួបគាត់ឡើយ[140]។ ហេតុនេះ ខ្ញុំជឿជាក់ថា ភាពអាចជឿជាក់បាននៃភស្តុតាងរបស់សាក្សី ទាក់ទងនឹងតួនាទីរបស់ អោ អាន អាចធ្វើការវាយតម្លៃបានត្រឹមត្រូវដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយ។

៩៤. មេធាវីការពារក្តី ក៏ប្តឹងដែរថា កំណត់ហេតុស្តាប់ចម្លើយ បំផ្លើសភស្តុតាងរបស់សាក្សី ដោយកត់ត្រាថា សាក្សីបានឮថា អោ អាន គឺជា *"ប្រធានគណៈតំបន់"* [141] ខណៈដែល សាក្សីបានបញ្ជាក់ថា *"តា អាន ទំនងជាគណៈតំបន់"*[142]។ នេះគឺជាបញ្ហាទូទៅមួយនៅក្នុងការស្តាប់

---

[136] សំណុំរឿង ០០៤ ឯកសារ D107/8 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹម កុល* ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN00784986។

[137] ដូចជើងទំព័រខាងលើ ERN00784987។

[138] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.២ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)។

[139] សំណុំរឿង ០០៤ ឯកសារ D3/15 *កំណត់ហេតុនៃការស្តាប់ចម្លើយ ដួង ស៊ីម* ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០ ERN00619831។

[140] ដូចជើងទំព័រខាងលើ។

[141] សំណុំរឿង ០០៤ ឯកសារ D3/15 *កំណត់ហេតុនៃការស្តាប់ចម្លើយ ដួង ស៊ីម* ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០ ERN00619831។

[142] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.៣ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដួង ស៊ីម (D3/15)។

ចម្លើយដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដូចបានបង្ហាញខាងលើ[143]។ អ្នកបកប្រែផ្ទាល់មាត់ ដែលជួយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ព្រមទាំងបុគ្គលិកខ្មែរនៅ ក.ស.ច.ស បានពន្យល់ថា សាក្សី ជាទូទៅសំដៅលើប្រធានគណៈតំបន់ណាមួយ ថាជា "គណៈតំបន់"។ និយាយម្យ៉ាងទៀត សាក្សីជាច្រើននាក់ កំណត់អត្តសញ្ញាណថា ជនដែលជាប្រធានថ្នាក់រដ្ឋបាលណាមួយ គឺជាថ្នាក់រដ្ឋបាល។ ដោយផ្អែកលើមូលដ្ឋាននេះ ខ្ញុំជឿជាក់ថា ក្នុងករណីនេះ ភស្តុតាងរបស់សាក្សី ត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។

*ការស្តាប់ចម្លើយសាក្សី សេង ស៊្រុន ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ (D76)*

៩៥. នៅក្នុងការស្តាប់ចម្លើយនេះ សាក្សីបានបញ្ជាក់ថា គាត់មិនបានស្គាល់អត្តសញ្ញាណរបស់អ្នកចូលរួមប្រជុំ ដែល អោ អាន មានវត្តមានទេ ពីព្រោះថា ពួកគេមកពីកន្លែងផ្សេងទៀតនៅកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែ ដូចមេធាវីការពារក្តី បានបញ្ជាក់យ៉ាងត្រឹមត្រូវ ដែរយោងតាមកំណត់ហេតុស្តាប់ចម្លើយ សាក្សីបានបញ្ជាក់ថា គាត់មិនបានស្គាល់អត្តសញ្ញាណអ្នកទាំងនោះឡើយ ពីព្រោះថា *"ពួកគេធំៗណាស់"*[144]។ កំហុសឆ្គងនេះគឺពាក់ព័ន្ធនឹងខ្លឹមសារនៃការស្តាប់ចម្លើយ ពីព្រោះថា វត្តមានរបស់ អោ អាន នៅក្នុងអង្គប្រជុំណាមួយជាមួយនឹងកម្មាភិបាលតំណែងខ្ពស់មែនទែន អាចពាក់ព័ន្ធនឹងការវាយតម្លៃលើសិទ្ធិអំណាច ឥទ្ធិពល និងតួនាទីរបស់គាត់នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគកណ្តាល សម័យកម្ពុជាប្រជាធិបតេយ្យ។

*ការស្តាប់ចម្លើយសាក្សី ឃុន សារ៉េត ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១(D93)*

៩៦. នៅក្នុងការស្តាប់ចម្លើយនេះ សាក្សីបានបញ្ជាក់ថា អោ អាន "*នៅតំបន់ ៤១*"[145]។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយ កត់ត្រាថា អោ អាន"*កាន់ថ្នាក់តំបន់។ តំបន់នោះគឺតំបន់ ៤១*" ហេតុនេះគឺជាការធ្វើសេចក្តីសន្និដ្ឋានមួយដែលហួសពីភស្តុតាងរបស់សាក្សី[146]។

---

[143] *សូមមើលខាងលើ* កថាខណ្ឌ ៤៧។

[144] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ៣.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី សេង ស៊្រុន (D76)។

[145] សំណុំរឿង ០០៤ ឯកសារ D93R *ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី ឃុន សារ៉េត* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ម៉ោង ០០.០៦.៥០-០០.០៧.១៥។

[146] ឧបសម្ព័ន្ធ ខ វិការៈដែលចោទ ១.១ ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន សារ៉េត (D93)។

## គ. សេចក្ដីសន្និដ្ឋានអំពីការវិភាគវិការៈដែលបានចោទ

៩៧. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចេញសេចក្ដីណែនាំឲ្យអ្នកស៊ើបអង្កេត ធ្វើកំណត់ហេតុស្ដាប់ចម្លើយដែលផ្ទុះបញ្ចាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននូវខ្លឹមសារដូចដើមនៃការស្ដាប់ចម្លើយ[147] ប៉ុន្តែ តាមច្បាប់ កំណត់ហេតុស្ដាប់ចម្លើយ មិនចាំបាច់ត្រូវតែកត់ត្រាឲ្យដូចដើមនៃភស្តុតាងរបស់សាក្សីឡើយ។ គ្រប់គ្រាន់ត្រឹមថា កំណត់ហេតុនោះគឺជាសេចក្ដីសង្ខេបយ៉ាងត្រឹមត្រូវនៃការស្ដាប់ចម្លើយ។ ហេតុនេះ ភាពខុសគ្នាមួយចំនួនរវាងខ្សែអាត់សំឡេង ជាមួយនឹងកំណត់ហេតុស្ដាប់ចម្លើយដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការចេញសេចក្ដីណែនាំទាំងនោះអាចរំពឹងថាកើតមានឡើង។ ប៉ុន្តែ ភាពខុសគ្នាបែបនេះក្លាយជាបញ្ហា តែក្នុងករណីដែលភាពខុសគ្នានេះប្រាសចាកពីពាក្យពេចន៍ជាក់ស្ដែងដែលបាននិយាយនៅក្នុងអំឡុងពេលស្ដាប់ចម្លើយ រហូតដល់កម្រិតមួយដែលភស្តុតាងដែលសាក្សីបានផ្ដល់ឲ្យមានការបំភាន់ខ្លឹមសារ ឬក្នុងកាលៈទេសៈដែលពាក់ព័ន្ធនឹងភាពអាចជឿជាក់បាន ឬអាចទុកចិត្តបានរបស់សាក្សី ហើយត្រូវបានលុបចេញ ឬបំប្លែង។

៩៨. នៅពេលដែលខ្ញុំត្រួតពិនិត្យមើលវិការៈដែលមេធាវីការពារក្ដី បានចោទ ខ្ញុំរកឃើញតែករណីមួយចំនួនតូចប៉ុណ្ណោះដែលភស្តុតាងរបស់សាក្សី ត្រូវបានបំប្លែង ឬភស្តុតាងពាក់ព័ន្ធមិនបានបញ្ចូលទៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ។ ប៉ុន្តែ ទោះជាក្នុងករណីបែបនេះក្ដី នៅពេលដែលអានខ្លឹមសារកំណត់ហេតុស្ដាប់ចម្លើយទាំងស្រុង បង្ហាញឲ្យឃើញថា ការបំប្លែង និងការលុបចោលព័ត៌មាន ជារឿយៗមិនមានលក្ខណៈធ្ងន់ធ្ងរ ឬជាក់ស្ដែងសំខាន់ឡើយ[148]។ ជាងនេះទៀត ចំពោះការបំប្លែងភស្តុតាងរបស់សាក្សីណាម្នាក់[149] ក៏ត្រូវពិចារណាឲ្យបានត្រឹមត្រូវផងដែរទៅលើអង្គហេតុដែលថា សាក្សី ត្រួតពិនិត្យឡើងវិញលើកំណត់ហេតុស្ដាប់ចម្លើយទាំងស្រុង មុនពេលផ្ដល់ឱកាសឲ្យធ្វើការកែតម្រូវ ហើយចុងក្រោយ គាត់ចុះហត្ថលេខាលើទំព័រនីមួយៗនៃ

---

[147] សំណុំរឿង ០០៤ ឯកសារ D269 *សេចក្ដីណែនាំស្ដីពីការសម្រិតសម្រាំងដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្ដីពីទម្រង់នៃកំណត់ហេតុស្ដាប់ចម្លើយ* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥។

[148] *សូមមើល* ផ្នែក III (ខ)(iii) ខាងលើ។

[149] សំអាងហេតុសម្រាប់ការចោទប្រកាន់អំពីការបំប្លែងភស្តុតាងមិនអាចប្រើប្រាស់បានដូចគ្នាជាមួយនឹងករណីការមិនបានបញ្ចូលភស្តុតាងឡើយ ពីព្រោះថា សាក្សីមិនសូវជាទំនងកត់សម្គាល់បានថា មានអ្វីបាត់ពីកំណត់ហេតុស្ដាប់ចម្លើយទេ ប៉ុន្តែគាត់ទំនងជាកត់សម្គាល់បានជាងប្រសិនបើចម្លើយរបស់គាត់កត់ត្រាមិនបានត្រឹមត្រូវ ឬខុស។

កំណត់ហេតុស្តាប់ចម្លើយ ដូច្នេះគាត់បានទទួលស្គាល់ពីភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយ។

៩៩. វិធានផ្ទៃក្នុង មិនតម្រូវថា ស.ច.ស ត្រូវធ្វើប្រតិចារឹក និងបកប្រែខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយឡើយ[150]។ តាមករណីនីមួយៗ ស.ច.ស គឺជាអ្នកកំណត់ថាតើចាំបាច់ត្រូវបង្គាប់ឱ្យធ្វើប្រតិចារឹក និងបកប្រែខ្សែអាត់សំឡេងណាមួយទាំងស្រុង ឬផ្នែកខ្លះ[151]។ ហេតុនេះ ការធ្វើប្រតិចារឹកខ្សែអាត់សំឡេង គឺជាវិធានការពិសេស។

១០០. ដោយផ្អែកលើមូលដ្ឋាននៃការវិភាគរបស់ខ្ញុំទៅលើវិការៈដែលបានចោទនៅក្នុងឧបសម្ព័ន្ធ ក និង ខ ភ្ជាប់ជាមួយនឹងសំណើ ខ្ញុំមិនជឿជាក់ថា មេធាវីការពារក្តី បានបង្ហាញពីអត្ថិភាពនៃឧទាហរណ៍អំពី“*ការអនុវត្តកិច្ចស៊ើបសួរដោយពុំត្រឹមត្រូវដែលមានជាច្រើនចំណុច និងគួរឱ្យកត់សម្គាល់*”[152]ទេ។ តាមការវិភាគរបស់ខ្ញុំ ខ្ញុំយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញនៅឧបសម្ព័ន្ធ ក និង ខ ជាទូទៅគឺត្រឹមត្រូវ ពេញលេញ អាចជឿជាក់បាន និងអនុវត្តតាមវិធានដែលចែងអំពីកំណត់ហេតុស្តាប់ចម្លើយនៅ អ.វ.ត.ក។ ហេតុនេះ ខ្ញុំមិនជឿថា មេធាវីការពារក្តី បានបង្ហាញថាមាន“ភាពចាំបាច់ពិតប្រាកដ”[153]ត្រូវធ្វើប្រតិចារឹក និងបកប្រែទាំងស្រុងនូវកំណត់ហេតុស្តាប់ចម្លើយដែលមេធាវីការពារក្តី បានបង្ហាញនៅក្នុងឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយសំណើ នោះឡើយ។

១០១. មេធាវីការពារក្តី បានស្នើសុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេងចំនួន ២១ នៃការស្តាប់ចម្លើយ[154]។ មេធាវីការពារក្តី អាចត្រួតពិនិត្យឡើងវិញលើខ្សែអាត់សំឡេងទាំងនេះ ដោយប្រើ

---

[150] *សូមមើល* សំណុំរឿង ០០២ ឯកសារ E142/3 *សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស* ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៦។

[151] សំណុំរឿង ០០២ ឯកសារ D194/2 *ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារឹក* ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១១។ សំណុំរឿង ០០២ ឯកសារ D194/3/2 *សាលដីកាបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើសុំធ្វើប្រតិចារឹក* ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០។

[152] *សូមមើល* សំណើ កថាខណ្ឌ ៥។

[153] សំណើ កថាខណ្ឌ ៣៣។

[154] *សូមមើល* ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយនឹងសំណើ។

ប្រាស់ធនធានខ្លួនឯង។ ប្រសិនបើមេធាវីការពារក្តី រកឃើញភាពខុសគ្នាគួរឲ្យកត់សម្គាល់ មេធាវីការពារក្តី អាចជូនដំណឹង ស.ច.ស ហើយ ស.ច.ស នឹងវាយតម្លៃការចោទប្រកាន់របស់មេធាវីការពារក្តី ហើយប្រសិនបើចាំបាច់ នឹងបង្គាប់ឲ្យធ្វើប្រតិចារឹកផ្នែកពាក់ព័ន្ធនានានៃខ្សែអាត់សំឡេងទាំងនោះ។

## ឃ. សំណើសុំដាក់ខ្សែអាត់សំឡេងមួយចំនួនចូលក្នុងសំណុំរឿង

១០២. ចំពោះសំណើរបស់មេធាវីការពារក្តី សុំដាក់ចូលក្នុងសំណុំរឿងនូវខ្សែអាត់សំឡេង D3/12, D3/13 និង D519/511.1.1 កំណត់ហេតុស្តាប់ចម្លើយទាំងនេះបង្ហាញថា ការស្តាប់ចម្លើយទាំងនេះត្រូវបានថតសំឡេង ប៉ុន្តែ មិនអាចរកឃើញខ្សែអាត់សំឡេងទាំងនោះទេ។

## ង. សំណើសុំដាក់ចូលក្នុងសំណុំរឿង ០០៤ នូវប្រតិចារឹក និងការបកប្រែការស្តាប់ចម្លើយដែលផ្ទេរពីសំណុំរឿងផ្សេងទៀត

១០៣. ជាគោលការណ៍ ខ្ញុំមិនមានការជំទាស់ឡើយក្នុងការដាក់ចូលក្នុងសំណុំរឿង ០០៤ នូវប្រតិចារឹកខ្សែអាត់សំឡេង និងការបកប្រែពាក់ព័ន្ធនានាដែលមានរួចហើយ។ នៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ ខ្ញុំបានបង្ហាញប្រតិចារឹក និងឯកសារបកប្រែមួយចំនួននៃការស្តាប់ចម្លើយទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយដែលផ្ទេរពីសំណុំរឿងផ្សេងទៀតចូលក្នុងសំណុំរឿង ០០៤ ហើយឯកសារទាំងនេះបច្ចុប្បន្ននេះមិនមាននៅក្នុងសំណុំរឿងឡើយ។ ខ្សែអាត់សំឡេងទាំងនេះត្រូវដាក់ចូលក្នុងសំណុំរឿង។

## តាមសំអាងហេតុខាងលើ ខ្ញុំ៖

១០៤. **បដិសេធ** សំណើត្រង់ចំណុចពាក់ព័ន្ធនឹងការបកប្រែ និងការធ្វើប្រតិចារឹកកំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយនឹងសំណើ។

១០៥. **ជូនដំណឹង** មេធាវីការពារក្តី ថា ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ D3/12, D3/13 និង D519/511.1.1 មិនអាចរកឃើញឡើយ។

១០៦. **បង្គាប់** ក្រឡាបញ្ជី ត្រូវដាក់ចូលក្នុងសំណុំរឿង ០០៤ នូវប្រតិចារឹក និងឯកសារបកប្រែខ្សែអាត់សំឡេងដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**